**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបការចាត់ចែងជាបណ្ដោះអាសន្ន រវាងប្រទេសកម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួច គីមយ៉េក**

**ហេង សុម៉ាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ ( អាហារូបករណ៍ )

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ប្រៀបធៀបការចាត់ចែងជាបណ្ដោះអាសន្ន រវាងប្រទេសកម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួច គឹមយ៉េក**

**ហេង សុម៉ាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧត្តី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ ( អាហារូបករណ៍ )

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

ៈៈៈៈៈៈៈៈៈៈៈៈ

ជាបឋម ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ អនុញ្ញាតឲ្យយើងខ្ញុំ សូមធ្វើការសម្តែងនូវកតញ្ញូ កតវេទីចំពោះលោកអ្នកដែលមានរាយនាមដូចខាងក្រោម៖

**មាតាបិតាទាំងទ្វេ** កូនសូមសម្តែងនូវមហាកតញ្ញូតាធម៌ជាអនេកប្បការ ដែលលោកបានផ្តល់កំណើតដល់រូបកូន ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀបប្រដៅរូបកូន ប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ទាំងបួន។ ជាងនេះទៅទៀតលោកអ្នកដ៏មានគុណទាំងទ្វេ បានពុះពារប្រឈមមុខរាល់ទុកលំបាកគ្រប់បែបយ៉ាង ដើម្បីឲ្យកូនទទួលបានការសិក្សារៀនសូត្ររហូតដល់បានបញ្ចប់ថ្នាក់ឧត្តមសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច** ជាគ្រឹះស្ថានភាពសិក្សាអប់រំដែលមិនត្រឹមតែផ្តល់នូវសាស្ត្រាចារ្យល្អៗ មានជំនាញក្នុងការផ្ទេរចំណេះដឹងពិតប្រាកដដល់ពួកយើងប៉ុណ្ណោះទេ ថែមជាកន្លែងជួយហាត់ពត់ លត់ដំចរិយាមាយាទ អប់រំស្មារតីឲ្យបណ្តុះខ្លួនក្លាយជាពលរដ្ឋល្អ ជាទំពាំងស្នងឬស្សីដែលប្រទេសជាតិមិនអាចខ្វះបាន។

**មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ជប៉ុន** (CJL) ជាកន្លែងបណ្តុះបណ្តាលធនធាននិស្សិតពិតប្រាកដឲ្យយល់ពីជម្រៅនៃការសិក្សារៀនសូត្រ ក៏ដូចជាស្វែងយល់បន្ថែមពីការសិក្សាស្រាវជ្រាវទាក់ទងនឹងវិស័យច្បាប់ និងជួយឲ្យយើងខ្ញុំមានការវិភាគបានស៊ីជម្រៅបន្ថែមមួយកម្រិតទៀតលើសារណាញុំាងឲ្យយើងខ្ញុំមានឱកាសក្នុងការប្រៀបធៀបរវាងប្រព័ន្ធច្បាប់កម្ពុជានិងជប៉ុនដូចមានសេចក្តីរៀបរាប់នៅក្នុងកិច្ចការសារណានេះ។

**លោក លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ចដែលបានចូលរួមរៀបចំ យកចិត្តទុកដាក់ក្នុងការបង្រៀន ដោយមិនខ្លាចនឿយហាត់ និងជំរុញផ្នែកស្មារតីឲ្យយើងខ្ញុំខិតខំរៀនសូត្រ ក្រេបជញ្ជក់យកចំណេះវិជ្ជា។

ជាពិសេសជាងនេះទៅទៀត សូមធ្វើថ្លែងអំណរគុណជូនចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧុធ្ធី** ជាគ្រូដឹកនាំសារណា ដែលបានជួយគាំទ្រយើងខ្ញុំយ៉ាងពេញទំហឹង ជាប្រទីបបំភ្លឺ តម្រង់ទិសជួយឲ្យយើងខ្ញុំមានវិធីសាស្ត្រកាន់តែច្បាស់លាស់ ធ្វើឲ្យកិច្ចការសារណានេះ លេចចេញជារូបរាងឡើង។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំសូមជូនពរដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

*៚៚៚៚*

ក្រោយពេលដែលយើងខ្ញុំបានសិក្សាអស់រយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្ររួចមក ធ្វើឲ្យយើងខ្ញុំបានទទួលចំណេះដឹង និងបទពិសោធន៍ល្អៗជាច្រើនពីថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យ។ ហើយនៅក្នុងសង្គមខ្មែរបច្ចុប្បន្នយើងជាក់ស្តែងមានការអនុវត្តច្រើនដែលទាក់ទងទៅនឹងការចាត់ចែងជាបណ្ដោះអាសន្ន ម្យ៉ាងទៀតវាមានការលំបាកយ៉ាងខ្លាំងនៅក្នុងស្វែងយល់អំពីនីតិវិធីនេះ ដែលតម្រូវឲ្យមានការសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែមទៀតដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន។

ទន្ទឹមនឹងការសិក្សាច្បាប់ជប៉ុនជាភាសាជប៉ុន យើងខ្ញុំក៏បានយល់ដឹងពីអត្ថន័យ ខ្លឹមសារនៃទ្រឹស្តី ព្រមទាំងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នរបស់ប្រទេសជប៉ុន ហើយបានមើលឃើញពីភាពខុសគ្នាឲ្យកត់សម្គាល់រវាងបញ្ញត្តិនៃប្រទេសទាំងពីរនេះ បើទោះបីជាកម្ពុជាបានទទួលឥទ្ធិពលច្បាប់ខាងរដ្ឋប្បវេណីពីជប៉ុនក្តីក៏មិនប្រាកដថានឹងមានលក្ខណៈដូចគ្នាទាំងអស់សុទ្ធសាធនោះទេ។ ក្នុងនាមជានិស្សិតច្បាប់ យើងខ្ញុំចង់ពាំនាំយកនូវបញ្ញត្តិបរទេសយកមកឲ្យអ្នកសិក្សាទាំងឡាយជួយពិនិត្យ ស្រាវជ្រាវទាំងអស់គ្នា ជួយពិចារណារួមគ្នា ថានឹងមានចំណុចណា ត្រូវយកជាគំរូមកសម្រួលច្បាប់ជាតិយើង ដើម្បីអភិវឌ្ឍវិស័យច្បាប់ឲ្យសមនឹងស្ថានភាពទូទៅរបស់ស្រុកទេសយើង។

ហេតុដូចដែលបានពោលខាងលើនេះហើយ ដែលជាកត្តាលីករជម្រុញទឹកចិត្តយើងខ្ញុំឲ្យជ្រើសយកប្រធានបទស្តីពី «**ប្រៀបធៀបការចាត់ចែងជាបណ្ដោះអាសន្នរវាងប្រទេសកម្ពុជា-ជប៉ុន**»យកមកធ្វើការវែកញែកជាបន្តបន្ទាប់ទៅនេះ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងក្លាយទៅជាចំណេះដឹងថ្មីរបស់អ្នកអានទាំងឡាយ ដោយហេតុថា ជាទូទៅយើងតែងយល់ពីច្បាប់កម្ពុជា ប៉ុន្តែមិនធានាថាយល់ដឹងអស់ពីច្បាប់បរទេសនោះទេ ក្នុងករណីនេះ គឺប្រទេសជប៉ុន។ យើងខ្ញុំនឹងព្យាយាមរំលេចឲ្យឃើញពីលក្ខណៈពិសេសប្លែក ដែលប្រព័ន្ធកម្ពុជាពុំទាន់មានបញ្ញត្តិយកមកអនុវត្ត ប៉ុន្តែមាននៅប្រទេសជប៉ុនរួចមកហើយ។ ទន្ទឹមនឹងនេះ សារណានេះនឹងជាប្រយោជន៍ដល់អ្នកសិក្សាឲ្យ ស្វែងយល់កាន់តែទូលំទូលាយអំពីការចាត់ចែងជាបណ្ដោះអាសន្នបន្ថែមទៀត។

យើងខ្ញុំសូមអភ័យទោសនូវកំហុសឆ្គងពាក្យពេចន៍ អក្ខរាវិរុទ្ធមួយចំនួន ឬ រាល់ចំណុចខ្វះខាតទាំងឡាយណាដែលកើតមានឡើងដោយចេតនាក្តី និងអចេតនាក្តី។ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យសារណានេះកាន់តែល្អប្រសើរឡើង។

# មាតិកា

ៜៜៜ

**ទំព័រ**

**សេចក្ដីផ្ដើម** ...... ០១

## ជំពូកទី១

## សញ្ញាណទូទៅ និងសមត្ថកិច្ចចេញដីកាចំពោះការចាត់ចែងជាបណ្ដោះអាសន្ន

**ផ្នែកទី១៖ សញ្ញាណទូទៅ** ...... ០៣

កថាភាគទី១៖ គោលបំណង ...... ០៣

ក.ប្រវត្តិនៃការចាត់ចែងជាបណ្ដោះអាសន្ន ...... ០៣

ខ.សារៈតានៃការចាត់ចែងជាបណ្ដោះអាសន្ន ...... ០៥

គ.លក្ខណៈពិសេស ...... ០៥

កថាភាគទី២៖ ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន ...... ០៥

ក. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ...... ០៦

ខ. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ...... ០៧

**ផ្នែកទី២៖ តុលាការដែលមានសមត្ថកិច្ច** ...... ០៧

កថាភាគទី១៖ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ...... ០៨

កថាភាគទី២៖ តុលាការដែលមានសមត្ថកិច្ច ...... ០៩

## ជំពូកទី២

## លក្ខណៈដូចនៃនីតិវិធី និងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន រវាងប្រទេសកម្ពុជា-ជប៉ុន

**ផ្នែកទី១៖ នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន** ...... ១១

កថាភាគទី១៖ លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្ន ...... ១១

ក.លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ...... ១១

ខ.លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ...... ១៣

កថាភាគទី២៖ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ...... ១៥

កថាភាគទី៣៖ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ...... ១៦

**ផ្នែកទី២៖ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន**.......................................................១៧
កថាភាគទី១៖ វិធីនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន .............................................................១៧
កថាភាគទី២៖ អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ......................................................១៨
**ផ្នែកទី៣៖ ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន** ...............................២០
កថាភាគទី១៖ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន .........................................២០
ក.ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន....................................................២០
ខ.ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន....................................................២២
គ.បណ្ដឹងជំទាស់.........................................................................................................២៣
កថាភាគទី២៖ អានុភាពនៃការលុបចោលដីកាចាត់ចែងជាបណ្ដោះអាសន្ន .........................................២៣
កថាភាគទី៣៖ ការលុបចោលការចាត់ចែងជាបណ្ដោះអាសន្នដោយសារស្ថានភាពពិសេស ..................២៤

## ជំពូកទី៣

## លក្ខណៈខុសគ្នានៃការចាត់ចែងជាបណ្ដោះអាសន្នរវាងប្រទេសកម្ពុជា-ជប៉ុន

**ផ្នែកទី១៖ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសជប៉ុន**.....................................................................២៧
កថាភាគទី១៖ ការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នក្នុងប្រទេសជប៉ុន ............២៧
ក. មូលហេតុនៃការដាក់ប្រាតិភោគ.......................................................................................២៨
ខ.មូលដ្ឋាននៃការដាក់ឬមិនដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ..........២៩
កថាភាគទី២៖ អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ .....................................៣១
កថាភាគទី៣៖ ការដាក់ពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ..............................................៣២
**ផ្នែកទី២៖ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសកម្ពុជា** ..........................................................................៣៣
កថាភាគទី១៖ ការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នក្នុងប្រទេសកម្ពុជា...........៣៣
កថាភាគទី២៖ អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុក្នុងករណីប្រទេសកម្ពុជា.......៣៤
កថាភាគទី៣៖ ការដាក់ពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ..............................................៣៤
**សេចក្ដីសន្និដ្ឋាន**.............................................................................................................៣៧
**អនុសាសន៍**.....................................................................................................................៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ការរស់នៅក្នុងសង្គមតែងតែមែងចាំបាច់មានការប្រាស្រ័យទាក់ទងគ្នា ដែលទំនាក់ទំនងនោះបង្កើតឱ្យមានអានុភាពគតិយុត្តិ គឺសិទ្ធិ និងកាតព្វកិច្ច។ ហើយរាល់ការទំនាក់ទំនងក្នុងសង្គមនោះ តែងតែបង្កើតឱ្យមានសិទ្ធិ និងកាតព្វកិច្ច ដែលកាតព្វកិច្ចនោះអាចនឹងកំណត់តាមច្បាប់ ឬឆន្ទៈរបស់ភាគី។[១] ជាក់ស្តែង វិវាទក៏តែងកើតមានឡើងដោយសារការរំលោភបំពានលើសិទ្ធិ ឬការមិនអនុវត្តកាតព្វកិច្ច ដែលពេលខ្លះទាមទារឱ្យមានដំណោះស្រាយ និងការការពារសិទ្ធិតាមរយៈតុលាការ។ ដូចនេះ នៅពេលមានវិវាទទាក់ទងសិទ្ធិ និងកាតព្វកិច្ច បុគ្គលដែលមានសិទ្ធិ អាចដាក់បណ្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីអនុវត្តនូវសិទ្ធិរបស់ខ្លួន។ ទោះបីជាយ៉ាងណាក្តី ការដោះស្រាយបណ្តឹងនីមួយៗ ត្រូវចាំបាច់អនុវត្តតាមនីតិវិធីដ៏ស្មុគស្មាញ និងចំណាយពេលយូររហូតដល់ចេញសាលក្រមជាស្ថាពរ ជាហេតុនាំឱ្យមានហានិភ័យដល់ម្ចាស់បំណុល ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។ មានន័យថា ម្ចាស់បំណុលនឹងពិបាកត្រូវបានធានាថាសិទ្ធិរបស់ខ្លួនអាចអនុវត្តនៅពេលអនាគត ឬពេលខ្លះអាចនឹងមិនអាចអនុវត្តបាន ដោយសារបម្រែបម្រួលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងនីតិវិធីបណ្តឹង។ ដូចនេះ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើងដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៦ ក្នុងគន្ថីទី៧ ដោយចែងកំណត់អំពី **ការចាត់ចែងរក្សាការពារ** ដែលអាចសម្របសម្រួលដល់ស្ថានភាពហានិភ័យនោះ។ ហើយបណ្តឹងទាក់ទងនឹងការចាត់ចែងរក្សាការពារក្នុងប្រទេសកម្ពុជា ក៏មានចំនួនគួរឱ្យកត់សម្គាល់។ ជាក់ស្តែងក្នុងឆ្នាំ២០១៦ ចំនួនបណ្តឹងរដ្ឋប្បវេណីដែលបានទទួលដោះស្រាយសរុបប្រហែល ២ម៉ឺនបណ្តឹង ហើយគេឃើញថា បណ្តឹងទាមទាររក្សាការពារមានចំនួនប្រហែល២១០០ករណី។[២]

ទោះបីជានីតិវិធីទាក់ទងនឹងការចាត់ចែងរក្សាការពារត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាមានរយៈពេល១០ជាងឆ្នាំក្តី ក៏វានៅតែមានចំណោទបញ្ហាមួយចំនួនទាក់ទងនឹង ការបកស្រាយច្បាប់ និង ការអនុវត្តនីតិវិធីនេះ។[៣]

[១] ក្រមរដ្ឋប្បវេណី, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣០៩។

[២] Nakayama,「カンボジアの司法 ～始審裁判所～(‘ប្រព័ន្ធតុលាការកម្ពុជា សាលាដំបូង’), ICD NEW, ខែធ្នូ ឆ្នាំ២០១៧,ទំព័រ៣

[៣] កម្មវិធីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាល ផ្នែករដ្ឋប្បវេណីនៅសាលាភូមិន្ទចៅក្រម. «សំនួរដែលត្រូវបានគេសួរញឹកញាប់ ស្តីពីការចាត់ចែងរក្សាការពារ» បោះពុម្ព ខែឧសភា ឆ្នាំ២០០៩។

ក្នុងនោះមានចំណោទបញ្ហាដែលគេលើកឡើងថា តើមានការដាក់ ឬ មិនដាក់ប្រាតិភោគតាមដីកាសម្រេចការពារ? តើមានការអនុវត្ត ឬ មិនមានការអនុវត្តការរក្សាការពារក្នុងអំឡុងពេលបណ្ដឹងជំទាស់? តើការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុមានអានុភាពបែបណាដែរ? ដូចនេះ ដើម្បីសិក្សា និងបកស្រាយចំណោទបញ្ហាទាំងនេះ យើងគប្បីយល់អំពីសញ្ញាណ និងនីតិវិធីនៃការចាត់ចែងរក្សាការពារជាមុនសិន។

ដោយហេតុថា **ការចាត់ចែងរក្សាការពារ** នេះ រួមមាន**ការរឹបអូសជាបណ្ដោះអាសន្ន** និង **ការចាត់ចែងជាបណ្ដោះអាសន្ន** ហើយការលើកយកការចាត់ចែងរក្សាការពារមកបកស្រាយតែម្ដង គឺជាប្រធានបទដែលមានលក្ខណៈទូលំទូលាយ ម្យ៉ាងវិញទៀតដោយសារភាពខ្វះខាតអត្ថបទស្រាវជ្រាវលម្អិតអំពីការចាត់ចែងជាបណ្ដោះអាសន្នជាភាសាខ្មែរ នោះដែនកំណត់នៃអត្ថបទស្រាវជ្រាវនេះ នឹងលើកយកតែ **ការចាត់ចែងជាបណ្ដោះអាសន្ន** មកធ្វើការសិក្សាតែប៉ុណ្ណោះ។ បន្ថែមពីនេះទៅទៀត អត្ថន័យនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មានលក្ខណៈស្រដៀងនឹងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន អត្ថបទស្រាវជ្រាវនេះនឹងធ្វើការពន្យល់ទាក់ទងនឹងការចាត់ចែងជាបណ្ដោះអាសន្ន ដោយសិក្សា និងមើលលំនាំតាមអត្ថបទបកស្រាយទាក់ទងនឹងការជំនុំជម្រះប្រទេសជប៉ុន រួមទាំងធ្វើការប្រៀបធៀបនឹងនីតិវិធីការចាត់ចែងជាបណ្ដោះអាសន្ននៃច្បាប់ជប៉ុន។ ដូចនេះ អត្ថបទនេះអាចជួយដល់អ្នកអានមានការយល់ដឹងកាន់ច្បាស់នឹងការចាត់ចែងរក្សាការពារ រួមទាំងនីតិវិធីពាក់ព័ន្ធផងដែរ។

ក្នុងការសិក្សាការចាត់ចែងជាបណ្ដោះអាសន្នឱ្យបានស៊ីជម្រៅ និងធ្វើការប្រៀបធៀបរវាងច្បាប់ប្រទេសកម្ពុជា និងប្រទេសជប៉ុន ប្លង់នៃការសិក្សានេះត្រូវបានបែងចែកជាបីជំពូកគឺ៖

**ជំពូកទី១៖** សញ្ញាណទូទៅ និងសមត្ថកិច្ចចេញដីកាចំពោះការចាត់ចែងជាបណ្ដោះអាសន្ន ដែលចែកចេញជា២ផ្នែកទៀតគឺ ផ្នែកទី១ សញ្ញាណទូទៅ និងផ្នែកទី២ តុលាការដែលមានសមត្ថកិច្ច

**ជំពូកទី២៖** លក្ខណៈដូចនៃនីតិវិធី និងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន រវាងប្រទេសកម្ពុជា និងជប៉ុន ដែលចែកចេញជា៣ផ្នែកទៀតគឺ ផ្នែកទី១ នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នផ្នែកទី២ ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន និងផ្នែកទី៣ ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**ជំពូកទី៣៖** លក្ខណៈខុសគ្នានៃការចាត់ចែងជាបណ្ដោះអាសន្នរវាងប្រទេសកម្ពុជា និងជប៉ុន ដែលចែកចែញជា២ផ្នែកទៀតគឺ ផ្នែកទី១ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសជប៉ុន និងផ្នែកទី២ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសកម្ពុជា។

# ជំពូកទី១

# សញ្ញាណទូទៅ និងសមត្ថកិច្ចចេញដីកាចំពោះការចាត់ចែងជាបណ្ដោះអាសន្ន

ជាទូទៅ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងដោះស្រាយវិវាទរវាងគូភាគី និងការពារសិទ្ធិបុគ្គលឯកជន ហើយមានការទទួលស្គាល់តាមផ្លូវច្បាប់តាមរយៈក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ ដោយសារមានស្ថានភាពមួយចំនួន ដែលមិនអាចឱ្យម្ចាស់បំណុលរងចាំរហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរជាមុន ដើម្បីទទួលបានការអនុវត្តសិទ្ធិនោះទេ។ ហេតុនេះ ដើម្បីបង្ការទប់ស្កាត់ជាមុននូវបញ្ហាឋានៈបុគ្គលរបស់បុគ្គល ដោយស្ថានភាពមួយចំនួនបុគ្គលដែលរងគ្រោះ ឬបុគ្គលមួយចំនួនដែលត្រូវការមាននីតិវិធីមួយចាំបាច់ក្នុងការកំណត់ឋានៈរបស់ពួកគេជាមុន ដើម្បីការពារស្ថានការបន្ទាន់ និងទទួលបានការសង្គ្រោះឱ្យសមស្របទៅនឹងពេលវេលា។ ដូចនេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមានប្រព័ន្ធមួយហៅថា ការចាត់ចែងជាបណ្ដោះអាសន្ន។

នៅក្នុងជំពូកនេះមានបែងចែកជា២ផ្នែក ដែលក្នុងផ្នែកទី១ យើងនិយាយអំពី សញ្ញាណទូទៅ ដោយក្នុងផ្នែកនេះដែរនឹងមានការសិក្សាទៅលើ សារតានៃការចាត់ចែងជាបណ្ដោះអាសន្ន និងប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន។ ចំពោះផ្នែកទី២ យើងនឹងបង្ហាញអំពី តុលាការដែលមានសមត្ថកិច្ចក្នុងការចាត់ចែងរក្សាការពារ ដោយក្នុងផ្នែកនេះនឹងចែកចេញជា២កថាភាគ គឺតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី (កថាភាគទី១) និងតុលាការដែលមានសមត្ថកិច្ចក្នុងការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន (កថាភាគទី២)។

## ផ្នែកទី១៖ សញ្ញាណទូទៅ

ការចាត់ចែងជាបណ្ដោះអាសន្ន ជាប្រភេទមួយនៃការចាត់ចែងរក្សាការពារ ដែលជានីតិវិធីមួយធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវបានរក្សាការពារ គឺជាសិទ្ធិក្រៅពីសិទ្ធិទាមទារឱ្យសងជាប្រាក់។[៤]

តើការចាត់ចែងជាបណ្ដោះអាសន្ននេះ មានសារតា និងអត្ថន័យយ៉ាងដូចម្ដេច?

### កថាភាគទី១៖ គោលបំណង

#### ក. ប្រវត្តិនៃការចាត់ចែងជាបណ្ដោះអាសន្ន

របបនៃការចាត់ចែងជាបណ្ដោះអាសន្នមានប្រភពចេញពីរបបទាក់ទង «ការបញ្ជាឱ្យផ្អាកដំណើរកាល

[៤] ក្រសួងយុត្តិធម៌. សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី(ភាគ២). ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០០៨, ទំព័រ១៩៣។

សាងសង់» នៅក្នុងរ៉ូម៉ាំង។[៥] ដោយសារភាពយឺតយ៉ាវនៃការដាក់ចេញនូវបទបញ្ជាម្តងៗ របបនេះបានវិវឌ្ឍឱ្យមានរបបមួយថ្មី ដែលស្តីអំពី «បណ្តឹងទាមទារកាន់កាប់ជាបណ្តោះអាសន្ន» នៅក្នុងប្រទេសអ៊ីតាលី នៅពាក់កណ្តាលសតវត្ស។ របបនេះ គឺជារបបមួយដែលនៅពេលមានបណ្តឹងទាក់ទងនឹងអចលនវត្ថុ ដោយពេលម្ចាស់បំណុលមានការទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវសិទ្ធិលើអចលនវត្ថុរបស់ខ្លួន នោះចៅក្រមអាចចេញដីកាសម្រេចក្នុងការហាមឃាត់ដល់ភាគីម្ខាងទៀត ក្នុងការការរំលោភបំពានលើសិទ្ធិលើអចលនវត្ថុនោះតាមសំណូមពររបស់ភាគី ប្រសិនបើខ្លួនយល់ថាមានភាពចាំបាច់។ [៦]

រហូតមកដល់ឆ្នាំ១៨៧៧ គេឃើញថា ក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសអាល្លឺម៉ង់ចាស់មាត្រា៨១៥ ដល់មាត្រា៨១៩ ដែលមានកំណត់ទាក់ទងនឹងការចាត់ចែងជាបណ្តោះអាសន្ន ដើម្បីធានាការពារការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុល។ ហើយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីចាស់នៃប្រទេសជប៉ុន សម័យមេជី បានយកលំនាំតាមច្បាប់អាឡឺម៉ង់ រួមទាំងការទទួលយកនូវរបបការចាត់ចែងជាបណ្តោះអាសន្ននេះ ដោយចែងក្នុងគន្ថីទី៦។ ទោះបីជាមានការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសជប៉ុនក្នុងឆ្នាំ១៩២៦ក្តី ក៏គេឃើញថាគន្ថីស្តីអំពីការចាត់ចែងជាបណ្តោះអាសន្នមិនមានការកែប្រែអ្វីឡើយ។ [៧] នៅក្នុងឆ្នាំ១៩៨៩ ប្រទេសជប៉ុនបានបង្កើតឱ្យមានច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីដែលបានចែងលម្អិតអំពីការចាត់ចែងជាបណ្តោះអាសន្ន និងនីតិវិធីពាក់ព័ន្ធ។ ហើយច្បាប់នេះដែរ មានឥទ្ធិពលយ៉ាងខ្លាំងដល់ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៦ ដោយកំណត់អំពី ការចាត់ចែងជាបណ្តោះអាសន្ន នៅក្នុងគន្ថីទី៧ នេះដែលយើងនឹងយកមកសិក្សាប្រៀបធៀប។

---

[៥]គឺជារបបមួយ ដែលនៅពេលគម្រោងសាងសង់នៅក្បែរអចលនាវត្ថុរបស់ខ្លួន ដោយម្ចាស់អចលនវត្ថុនោះមានការព្រួយបារម្ភថា គម្រោងសាងសង់នោះអាចប៉ះពាល់ដល់ការអនុវត្តសិទ្ធិលើអចលនវត្ថុរបស់ខ្លួន នោះម្ចាស់អចលនវត្ថុអាចទាមទារឱ្យចេញនូវបទបញ្ជាផ្អាកដំណើរការគម្រោងសាងសង់នោះបាន។

[៦] Engelmann. លោក ណាកាអោ តេអ៊ុយឈិអោ, ប្រែសម្រួល *«ប្រវត្តិសង្ខេបនៃក្រមនីតិវិធីរដ្ឋប្បវេណី»* បោះពុម្ពឆ្នាំ ២០០៧, ទំព័រ ៣៣៥ ដល់ ៣៣៦។

[៧]Yokomichi shunnichi ,«ការសិក្សាទៅលើមាត្រា២៣វាក្យខណ្ឌ៤នៃច្បាប់ស្តីពីការចាត់ចែងរក្សាការពារ». Keio law Journal 28(កុម្ភះ ឆ្នាំ ២០១៤ ). ទំព័រ ៤៣២។

**ខ.សារសំខាន់នៃការចាត់ចែងជាបណ្ដោះអាសន្ន**

ការចាត់ចែងជាបណ្ដោះអាសន្ននេះ មានគោលបំណងការពារ និងថែរក្សាស្ថានភាពដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារបុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិតាមរយៈការទាមទាររបស់បុគ្គលនោះ។[៨]

ដូចនេះ ទោះបីជាការចាប់ផ្ដើមអនុវត្តដោយបង្ខំតម្រូវឱ្យបំពេញនូវល័ក្ខខណ្ឌ ដូចជា អត្ថិភាពនៃលិខិតអនុវត្ត និង ការមកដល់នៃពេលកំណត់អនុវត្តកាតព្វកិច្ចក៏ដោយរបបស្ដីពី ការចាត់ចែងជាបណ្ដោះអាសន្នអាចទប់ស្កាត់ជាមុនដោយមិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្ដែងក្នុងគោលដៅធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។

**គ.លក្ខណៈពិសេស**

ការចាត់ចែងជាបណ្ដោះអាសន្ន គឺមានលក្ខណៈពិសេសជាងនីតិវិធីបណ្ដឹងអង្គសេចក្ដី ឬ នីតិវិធីអនុវត្តដោយបង្ខំដោយសារមូលហេតុពីរ។ ទីមួយគឺ បណ្ដឹងអង្គសេចក្ដីប្រើពេលវេលាយូរណាស់ បើគិតតាំងពីពេលដាក់ពាក្យបណ្ដឹងរហូតដល់ពេលចេញសាលក្រម និងចូលជាស្ថាពរ។ មូលហេតុទីពីរគឺ ដំណើរការនីតិវិធីបណ្ដឹងប្រសិនបើមានការប្រែប្រួលនូវស្ថានភាពឋានៈរបស់ភាគីណាម្ខាងនោះ ទោះជាម្ចាស់បំណុលបានឈ្នះក្ដីក៏មិនអាចអនុវត្តដោយបង្ខំបានដែរ។ ដើម្បីបង្ការកុំអោយមានបញ្ហាទាំងនេះ គេបង្កើតអោយមានយន្តការសង្គ្រោះជាបណ្ដោះអាសន្ន រហូតដល់សិទ្ធិត្រូវបានសម្រេចជាស្ថាពរដោយសាលក្រម ឬសាលដីកាស្ថាពរ។ ដូចនេះ នីតិវិធីចាត់ចែងជាបណ្ដោះអាសន្ននេះមានចរិកលក្ខណៈជាវិធីបណ្ដោះអាសន្ន បន្ទាប់បន្សំ បន្ទាន់ និងសម្ងាត់។[៩]

**កថាភាគទី២៖ ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន**

ការចាត់ចែងជាបណ្ដោះអាសន្នមានពីរប្រភេទ៖ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។ ទោះបីជាមានគោលបំណង និង ចរិតលក្ខណៈខុសគ្នាក៏ដោយ ក៏ការចាត់ចែងជាបណ្ដោះអាសន្នទាំងពីរនេះ ស្ថិតនៅក្នុងប្រភេទនៃការ

[៨] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា ៥៣០។

[៩] សួង សុភា, ថៅប៊ុនហួន. «នីតិវិធីនៃការចាត់ចែងរក្សាការពារ»ឆ្នាំ២០១៧ ទំព័រ ២។

ចាត់ចែងរក្សាការពារ ហើយសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសងជាប្រាក់ដូចគ្នា។ ហេតុនេះហើយ ការចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះ ត្រូវធ្វើតាមនីតិវិធីដូចគ្នា។

**ក.ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ**

យោងតាមមាត្រា៥៣១ ចំនុច «ខ» បានចែងថា ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទគឺជា «ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ នៅពេលដែលម្ចាស់បំណុលបារម្ភថាខ្លួនមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ»។

ក្នុងករណីប្រទេសជប៉ុន ដោយយោងតាមច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី ដែលបានធ្វើការបែងចែកការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនេះជាពីរប្រភេទ គឺ«ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង» និង «ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់»។ ចំពោះប្រភេទទីមួយ «ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង» គឺសិទ្ធិដែលត្រូវការពារសំដៅលើសិទ្ធិទាមទារការចុះបញ្ជី ដើម្បីធានាទាំងសិទ្ធិទាមទារការចុះបញ្ជីការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុ[១០]និងសិទ្ធិទាមទារការចុះកម្មសិទ្ធិក្រៅពីកម្មសិទ្ធិ[១១] រួមជាមួយនឹងវត្ថុដែលអាចចុះបញ្ជី។[១២] រីឯប្រភេទទីពីរ «ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់» គឺសំដៅលើសិទ្ធិដែលត្រូវរក្សាការពារជាសិទ្ធិទាមទារប្រគល់វត្ថុ ដើម្បីធានានូវសិទ្ធិទាមទារប្រគល់វត្ថុនោះ។ [១៣]

[១០] ច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី, ២២ ធ្នូ ១៩៨៩,មាត្រា៥៣ វាក្យខណ្ឌ២ (ប្រភេទការពារនេះ ត្រូវអនុវត្តដោយធ្វើការ«ការចុះបញ្ជីការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង»នៅក្នុងសៀវភៅចុះបញ្ជី។)

[១១] ច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី, ២២ ធ្នូ ១៩៨៩, មាត្រា៥៣ វាក្យខណ្ឌ២ (សិទ្ធិក្រៅកម្មសិទ្ធិ គឺសំដៅលើសិទ្ធិលើហ៊ីប៉ូតែក ឬសិទ្ធិជួលអចិន្ត្រៃយ៍ជាដើម ដែលប្រភេទនេះ នឹងអនុវត្តដោយធ្វើការ«ការចុះបញ្ជីបណ្តោះអាសន្នលើការបង្កើតហ៊ីប៉ូតែក» ឬ«ការចុះបញ្ជីបណ្តោះអាសន្នលើការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍»។)

[១២] ច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី, ២២ ធ្នូ ១៩៨៩, មាត្រា៥៤ (វត្ថុដែលអាចចុះបញ្ជីក្រៅពីអចលនាវត្ថុ គឺសំដៅលើកប៉ាល់ យន្តហោះ។ល។)

[១៣] ច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី, ២២ ធ្នូ ១៩៨៩, មាត្រា២៥ វាក្យខណ្ឌ៣ ( គេអាចធានាសិទ្ធិនេះបាន ដែលត្រូវធ្វើការចាត់ចែងជាបណ្តោះអាសន្ន ដោយហាមឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់ ឬបង្គាប់ឱ្យកូនបំណុលបោះបង់ការកាន់កាប់ ឬបង្គាប់ឱ្យសាលាអាជ្ញារក្សាទុកនូវកម្មវត្ថុដែលមានវិវាទ។)

### ខ.ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺជា «ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ។[១៤]

ចំពោះការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះ គឺមិនមានកំណត់ច្បាស់ទេនៅក្នុងច្បាប់ប្រទេសជប៉ុន ប៉ុន្តែគេអាចនិយាយម្យ៉ាងទៀតថា ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺសំដៅលើការចាត់ចែងជាបណ្តោះអាសន្នទាំងឡាយ ដែលក្រៅពីប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទដែលបានលើកឡើងខាងលើ។

<u>ឧទាហរណ៍</u>៖ ការបង់ប្រាក់ជាបណ្តោះអាសន្ន

នៅពេលបុគ្គលិកម្នាក់ប្តឹងទៅចៅហ្វាយរបស់ខ្លួនអំពីការបញ្ឈប់ការងារដោយអយុត្តិធម៌ បុគ្គលិកនោះទាមទារការបង់ប្រាក់ខែជាបណ្តោះអាសន្ន ដោយសារភាពលំបាកខាងជីវភាពរបស់គាត់ មុនពេលសាលក្រមនៃបណ្តឹងអង្គសេចក្តីចេញ។ [១៥]

ដូចនេះ ដោយសារការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺអនុវត្តទៅតាមករណីផ្សេងៗគ្នា ដែលទាមទារឱ្យមានការស្វែងយល់ពីអង្គហេតុច្បាស់លាស់ និងមានចំណេះដឹងច្បាប់យ៉ាងមាំមួន រួមទាំងការធ្វើសេចក្តីសម្រេចដោយធ្វើការពិចារណាយ៉ាងប្រុងប្រយ័ត្ន។

## ផ្នែកទី២៖ តុលាការដែលមានសមត្ថកិច្ច

នៅពេលដែលបញ្ហាវិវាទកើតឡើង ហើយភាគីមិនអាចរកដំណោះស្រាយតាមការចរចា ឬ ផ្សះផ្សាដែលតម្រូវឱ្យជ្រើសរើសយកការដោះស្រាយតាមប្រព័ន្ធតុលាការ។ ដូចនេះ សមត្ថកិច្ចរបស់តុលាការ គឺវាមានសារៈសំខាន់ណាស់សម្រាប់ការវិនិច្ឆ័យចំពោះការចេញដីកាសម្រេចរក្សាការពារចំពោះការចាត់ចែងជាបណ្តោះអាសន្ននេះ។ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលពាក្យបណ្តឹងដោយស្របច្បាប់ និងវិនិច្ឆ័យ

---

[១៤] ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា៥៣១ ចំណុច«គ»។

[១៥] Yogohama law office,「仮の地位を定める仮処分について」 («ការចាត់ចែងជាបណ្តោះអាសន្ន») http://www.breeze.gr.jp/field/saikenkaisyu/minjihozen_syobun.html (បានចូលមើលចុងក្រោយ៖ ០៤ កក្កដា ២០២១)

រឿងក្តីហើយចេញសាលក្រម ឬសាលដីកាបាន។[16] នៅពេលម្ចាស់បំណុលបានដាក់ ពាក្យសុំទៅតុលាការណា មួយ តុលាការនោះត្រូវពិនិត្យមើលអត្ថិភាព ឬនិត្ថភាព និងទំនាក់ទំនងគតិយុត្តនៃសមត្ថកិច្ចរបស់ខ្លួនព្រមទាំង ភាពត្រឹមត្រូវនៃពាក្យសុំផង។ កាលបើតុលាការយល់ឃើញថាខ្លួនមិនមានសមត្ថកិច្ចលើរឿងក្តីនៃការចាត់ចែង រក្សាការពារចំពោះការចាត់ចែងជាបណ្តោះអាសន្ននោះទេ តុលាការនោះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមាន សមត្ថកិច្ចតាមរយៈពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ ដូចនេះ រឿងក្តីរក្សាការពារចំពោះការ ចាត់ចែងជាបណ្តោះអាសន្នត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី។

**កថាភាគទី១៖ តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី**

អង្គសេចក្តី គឺជារឿងក្តីនៃបណ្តឹងដែលពាក្យបណ្តឹងត្រូវបានដាក់ចំពោះសិទ្ធិលើបំណុល ដែលត្រូវបាន រក្សាការពារ។ មុននឹងពេលដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការមានសមត្ថកិច្ច គឺជាតុលាការដែលមានសមត្ថ កិច្ចលើរឿងក្តីនៃបណ្តឹងដែលនឹងធ្វើនាពេលអនាគត។ ជាគោលការណ៍ តុលាការដែលមានសមត្ថកិច្ចលើ អង្គ សេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើកទីមួយ ប៉ុន្តែបើអង្គសេចក្តីត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹង ឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។[17]

ចំពោះការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ តុលាការមានសមត្ថកិច្ច អាចជា តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីដូចដែលបានរៀបរាប់ខាងលើ ឬ សាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ។[18] ក្នុងករណីច្បាប់នៃប្រទេសជប៉ុន ក៏បានកំណត់នូវសមត្ថកិច្ច នៃតុលាការ ចំពោះការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនេះដែរ គឺជាគោលការណ៍ សំដៅលើតុលាការមានសមត្ថកិច្ចលើទីកន្លែងដែលជាកម្មវត្ថុនៃវិវាទនោះស្ថិតនៅ។[19]

---

[16] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា ៧។

[17] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី(ភាគ២)*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០០៨, ទំព័រ ១៩៧។

[18] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា៥៤០ វាក្យខណ្ឌ១ ។

[19] ច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី, ២២ ធ្នូ ១៩៨៩,មាត្រា១២ វាក្យខណ្ឌ១ ។

ផ្ទុយទៅវិញ ចំពោះការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នវិញ ការអនុវត្តនៅប្រទេសកម្ពុជា និងប្រទេសជប៉ុនគឺដូចគ្នា គឺតុលាការមានសមត្ថកិច្ចមានតែតុលាការនៃបណ្តឹងអង្គសេចក្តីតែប៉ុណ្ណោះ។ [២០]

## កថាភាគទី២៖ តុលាការដែលមានសមត្ថកិច្ច

យោងតាមមាត្រា៥៣២ វាក្យខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា តុលាការដែលត្រូវអនុវត្តការចាត់ចែងចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការចាត់ចែងរក្សាការពារ។ ដោយសារវិធីចាត់ចែងជាបណ្តោះអាសន្នមានច្រើន ដូចច្នេះពុំមានបញ្ញត្តិចែងឱ្យបានជាក់លាក់អំពីវិធាននៃការអនុវត្តទេ។ ដូចនេះ ចំពោះតុលាការមានសមត្ថកិច្ច ត្រូវស្របទៅតាមវិធីនៃការអនុវត្តនីមួយៗ ដែលមានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

ករណីការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យសងជាប្រាក់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ [២១] យោងតាមបញ្ញត្តិនៃការអនុវត្តដោយបង្ខំ យើងអាចសន្និដ្ឋានបានថា ស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមនៃសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជាតុលាការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន។

ករណីការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ ត្រូវធ្វើឡើងតាមរបៀបកាន់កាប់វត្ថុដែលដែលជាកម្មវត្ថុដោយ អាជ្ញាសាលា[២២] នៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។ [២៣] ចំពោះច្បាប់ជប៉ុនក៏ពុំមានចែងច្បាស់អំពី ស្ថាប័នមានសមត្ថកិច្ចក្តី បើ

[២០]តុលាការរដ្ឋប្បវេណីនៃតំបន់Hiroshima«លិខិតណែនាំទាក់ទងនឹងការដាក់បណ្តឹងចំពោះការចាត់ចែងរក្សាការពារ» ទំព័រ១០ https://www.courts.go.jp/hiroshima/vc-files/hiroshima/file/hozen08.pdf (បានចូលមើលចុងក្រោយ៖ ០៥ កក្កដា ២០២១)។

[២១] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី(ភាគ២).* ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០០៨, ទំព័រ២០៦។

[២២] អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយដែលទទួលបន្ទុកក្នុងការអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយមានមន្ត្រីរាជការដែលមានឈ្មោះថា អាជ្ញាសាលា។

[២៣] បញ្ញត្តិ គឺអនុលោមតាមវិធីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដែលមានចែងក្នុងមាត្រា៥៦៥កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

យោងតាមការអនុវត្តផ្ទាល់ គឺដូចទៅនឹងការអនុវត្តនៅប្រទេសកម្ពុជាដោយតុលាការមានសមត្ថកិច្ចក្នុងការអនុវត្ត គឺ តុលាការដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។[២៤]

ករណីដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ បើយោងតាមមាត្រា៥៧១ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីការអនុវត្តនេះ គឺការដកហូតការកាន់កាប់នោះហើយអាជ្ញាសាលាជាស្ថាប័នដែលត្រូវថែរក្សាគ្រប់គ្រងវត្ថុនោះតាមបង្គាប់របស់តុលាការមានសមត្ថកិច្ច។

[២៤] Mikura Hideo 「仮処分命令による登記」（«ការចុះបញ្ជីចំពោះការចាត់ចែងជាបណ្ដោះអាសន្ន»）ឆ្នាំ២០១៩ ទំព័រ១៤ https://www.tatsumi.co.jp/stream/documents/asakura_19012001_3.pdf (បានចូលមើលចុងក្រោយ ០៥ កក្កដា ឆ្នាំ២០២១។

# ជំពូកទី២

# លក្ខណៈដូចនៃនីតិវិធី និងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន រវាងប្រទេសកម្ពុជា-ជប៉ុន

ជាការពិតណាស់ ដោយសារកម្ពុជាបានទទួលជំនួយចងក្រងក្រមនីតិវិធីរដ្ឋប្បវេណីពីសំណាក់អ្នកជំនាញការនៃប្រទេសជប៉ុន ដែលជាហេតុនាំឱ្យមានការជះឥទ្ធិពលនៃគោលគំនិតផ្នែកនីតិវិធីរដ្ឋប្បវេណីមួយផ្នែកធំមកលើក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ តួយ៉ាង បទបញ្ញត្តិចែងទាក់ទងនឹង ការចាត់ចែងជាបណ្តោះអាសន្ន គឺបានមកពីច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីក្នុងឆ្នាំ១៩៨៩ ព្រោះថាក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសជប៉ុន មិនបានចែងអំពីការចាត់ចែងជាបណ្តោះអាសន្នឡើយ។ ចំណុចបន្តទៅនេះ នឹងលើកឡើងពីភាពដូចគ្នារវាង នីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន។

## ផ្នែកទី១៖ នីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន

### កថាភាគទី១៖ លក្ខខណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្ន

#### ក.លក្ខខណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ដើម្បីទទួលបានការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ តុលាការចាំបាច់ត្រូវពិនិត្យទៅលើការទាមទាររបស់ភាគីនោះស្របទៅនឹងលក្ខខណ្ឌនឹងលើកឡើងខាងក្រោមនេះទេ។ ហេតុនេះហើយ នៅពេលមានករណីទាមទារឱ្យធ្វើការចាត់ចែងជាបណ្តោះអាសន្នក្នុងប្រភេទនេះ អ្នកដាក់ពាក្យសុំត្រូវសរសេរ និងបញ្ជាក់ឱ្យបានច្បាស់នូវសិទ្ធិទាមទារនៅក្នុងពាក្យសុំ ដើម្បីងាយស្រួលដល់ការវិនិច្ឆ័យរបស់ចៅក្រម ដែលដូចគ្នានឹងការអនុវត្តក្នុងប្រទេសជប៉ុន។[២៥]

១. សិទ្ធដែលត្រូវបានរក្សាការពារ៖ សិទ្ធិដែលត្រូវរក្សាការពារ គឺសិទ្ធិទាមទារឲ្យប្រគល់វត្ថុ។ គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃការវិវាទ គឺដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនោះ។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយ ការចាត់ចែងជា

---

[២៥] http://www.kuma-office.jp/article/13515438.html?fbclid=IwAR1c-ghitCxmZxrdCmZimexApDmLTkn540IXAPM4uzB98cRl-IZ4gdwcZ0w(បានចូលមើលចុងក្រោយថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១)។

បណ្តោះអាសន្ននេះត្រូវមានខ្លឹមសារជាការផ្លាស់ប្តូរ ឬ មិនផ្លាស់ប្តូរនូវស្ថានភាពជាក់ស្តែង ឬ ទំនាក់ទំនងសិទ្ធិដែលមានលើវត្ថុ។[២៦] សិទ្ធិដែលត្រូវបានរក្សាការពារ រួមមាន សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារឲ្យបណ្តេញបុគ្គលចេញពីដី ឬ អាគារ សិទ្ធិទាមទារឲ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធទាមទារមិនឲ្យធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុជាអាទិ៍។

<u>ឧទាហរណ៍</u>៖ លោក «អ» បានជួលផ្ទះទៅឱ្យលោក «ឡ» ។ ប៉ុន្តែទោះបីជាលោក «អ» បានដាស់តឿនលោក«ឡ» ជាច្រើនដងក្តី ក៏លោក «ឡ» បានពន្យាពេលមិនព្រមបង់ថ្លៃជួលផ្ទះទៅឱ្យលោក «អ» ជាច្រើនខែក៏ «អ» សម្រេចចិត្តប្តឹងទាមទារឱ្យ លោក «ឡ» ប្រគល់ផ្ទះនោះមកវិញដោយអនុវត្តដោយបង្ខំ និងសងនូវប្រាក់ឈ្នួលដែលជំពាក់ទាំងប៉ុន្មានមកវិញ។ ជាក់ស្តែង ផ្ទះដែលជាកម្មវត្ថុនៃវិវាទនោះលោក «ឡ» បានធ្វើការជួលបន្តទៅឱ្យលោក «ហ» រួចហើយ។ ដូចនេះលោក «អ» អាចប្តឹងទាមទារឱ្យតុលាការធ្វើការចាត់ចែងជាបណ្តោះអាសន្នចំពោះផ្ទះដែលជាកម្មវត្ថុនៃវិវាទនោះទៅលើលោក «ហ» ដោយបញ្ជាក់ពីសិទ្ធិទាមទារឱ្យបណ្តេញបុគ្គលលោក «ហ» នោះចេញពីផ្ទះ។

គំរូនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ រួមមាន ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យបណ្តេញចេញពីអចលនវត្ថុនោះ ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុ ជាអាទិ៍។

២. ភាពចាំបាច់នៃការរក្សាការពារ៖ ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានទទួលស្គាល់ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ [២៧] ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ [២៨] ដូចឧទាហរណ៍លោក «អ» និងលោក «ឡ» ខាងលើនេះដោយមានការបារម្ភថាមានការប្រែ

[២៦] វត្ថុនេះហៅថា វត្ថុដែលជាកម្មវត្ថុនៃវិវាទ។

[២៧] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា ៥៣១ ចំណុចខ។

[២៨] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា ៥៤៨ កថាខណ្ឌទី១។

ប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះលោក «អ» អាចធ្វើការទាមទារការចាត់ចែងជាបណ្ដោះអាសន្ន។

ដូចនេះ ម្ចាស់បំណុលដែលទាមទារធ្វើការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីព័ត៌មានផ្សេងៗដែលបារម្ភថា កូនបំណុលនឹងផ្ទេរការកាន់កាប់ទៅតតិយជន។[២៩] ករណីនេះ រួមមានករណីដែលមានហានិភ័យនៃការខូចខាតការកែបំបាត់ ការផ្ទេរ ឬ ការរារាំងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយកូនបំណុល ឬ អ្នកផ្សេងករណីដែលបុគ្គលណាម្នាក់កំពុងបន្តដំណើរនៃការសាងសង់ ក្នុងខណៈដែលមានការទាមទារ ឲ្យដកចេញនូវការសាងសង់នោះ ការដែលបុគ្គលម្នាក់ផ្សេងទៀត រួមទាំងឥវ៉ាន់របស់គេមករស់នៅជាមួយក្នុងខណៈដែលមានការទាមទារឲ្យបណ្ដេញចេញពីផ្ទះនោះ។ ករណីដែលបុគ្គលម្នាក់ចាប់ផ្ដើមការសាបព្រួស ក្នុងខណៈដែលមានការទាមទារឲ្យប្រគល់ដី កសិកម្មនោះ ជាអាទិ៍។

## ខ.លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

ដូចគ្នានេះដែរ ចំពោះការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ននេះ អ្នកទាមទារចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីភាពចាំបាច់នៃសិទ្ធិរបស់ខ្លួន។

១. សិទ្ធិដែលត្រូវបានរក្សាការពារៈការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន រួមបញ្ចូលនូវការចាត់ចែងជាច្រើនប្រភេទ ដូចដែលមានចែងក្នុងកថាភាគទី២ នៃជំពូកទី១។ ហេតុនេះហើយ សិទ្ធិទាមទារដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះក៏មានច្រើនដែរ។ សិទ្ធិដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬ សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល។[៣០]

<u>ឧទាហរណ៍</u>៖ ទំនាក់ទំនងសិទ្ធិផ្ដាច់មុខ ដូចជា កម្មសិទ្ធិកាន់កាប់ សេរីភាព សិទ្ធិលើនាម និង សិទ្ធិលើប្រកាសនីយប័ត្រក្កកម្ម ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្សដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា និង កម្មសិទ្ធិអវិភាគ ទំនាក់ទំនងគតិយុត្តដែលបន្ត ដូចជាកិច្ចសន្យាក្រុមហ៊ុន ភតិសន្យាការងារ និង ការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) និង ទំនាក់ទំនងឋានៈបុគ្គលដូចជា ទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនងរវាងឪពុកម្ដាយ

---

[២៩] Yukawa Ryo «ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន» ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

[៣០] សិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល គឺជាសិទ្ធិនៃទំនាក់ទំនងនៃក្រុមគ្រួសារមានដូចជា ប្ដីប្រពន្ធ, ឪពុកម្ដាយកូន មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីទាក់ទងនឹងឋានៈបុគ្គល និងសេចក្ដីកំណត់ចំពោះមាត្រានីមួយៗឆ្នាំ ២០០៤។

និង កូន។ ចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឲ្យសងជាប្រាក់ ប្រសិនបើគោលបំណងនៃការរក្សាការពារ មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំនាពេលអនាគតទេ តែគឺ ដើម្បីទប់ស្កាត់ និង ដកចេញនូវគ្រោះថ្នាក់ ឬ ការខូចខាតពិសេសដែលកើតឡើងពីការមិនអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារនោះគេអាចទាមទារឲ្យផ្តល់តាវកាលិកទាំងស្រុង ឬ មួយផ្នែកតាមនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នបាន។

<u>ឧទាហរណ៍</u>៖ ករណីដែលបុគ្គលណាម្នាក់ពិបាកនឹងរស់នៅដោយគ្មានការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) ឬ ការបើកប្រាក់បៀវត្ស ករណីដែលបុគ្គលណាម្នាក់ពិបាកនិងទទួលបានការព្យាបាល ឬ មិនងាយនឹងជាពីជំងឺ ប្រសិនបើគ្មានការទទួលការសងប្រាក់ធានារ៉ាប់រង ជាអាទិ៍។

ត្រង់ចំណុចនេះ មានបញ្ហាមួយ ទាក់ទងទៅនឹង ការចាត់ចែងជាបណ្តោះអាសន្នដែល សម្រេចសិទ្ធិ តែម្តង។ ការចាត់ចែងបែបនេះ សំដៅទៅលើការចាត់ចែងជាបណ្តោះអាសន្នដែលសម្រេចតាមខ្លឹមសារនៃសិទ្ធិតែម្តងអាចមានលទ្ធផលដូចជា ការទទួលស្គាល់ការអនុវត្តជាបណ្តោះអាសន្ននោះអាចធ្វើឲ្យគេគិតថា ការសម្រេចនោះលើសពីគោលបំណងនៃការចាត់ចែងបណ្តោះអាសន្ន។ ក៏ប៉ុន្តែ ជាទូទៅការចាត់ចែងបែបនេះ ត្រូវបានចាត់ទុកថាស្របច្បាប់ ព្រោះថាការចាត់ចែងជាបណ្តោះអាសន្ន ដែលកំណត់ឋានៈជាបណ្តោះអាសន្ន មានគោលបំណងដើម្បីកំណត់ឋានៈជាបណ្តោះអាសន្ន ដោយផ្អែកលើការសន្មតថា សិទ្ធិទាមទារទាំងមូល ឬ មួយផ្នែកមានអត្ថិភាពក្នុងគោលបំណងដកចេញនូវគ្រោះថ្នាក់ពិសេស និង ក្តីបារម្ភដែលកើតមានចំពោះម្ចាស់បំណុល ពីការមិនសម្រេចសិទ្ធិទាមទារ ដោយសារមានវិវាទអំពីអត្ថិភាពនៃសិទ្ធិនោះ ហើយបង្គាប់ឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចនៃសិទ្ធិទាមទារនោះ។ មានន័យថា គោលបំណងរបស់វា មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំនាពេលអនាគតនោះទេ។

<u>ឧទាហរណ៍</u>៖ ករណីដែលនិយោជិត ដែលធ្វើការអះអាងអំពី មោឃភាពនៃការបណ្តេញចេញដោយនិយោជក សុំឲ្យធ្វើការចាត់ចែងជាបណ្តោះអាសន្ន ដោយបង្គាប់ឲ្យនិយោជកនោះ ផ្តល់ប្រាក់ខែឲ្យខ្លួនចំនួនពាក់កណ្តាល រហូតដល់ពេលដែលបណ្តឹងអង្គសេចក្តីត្រូវបានសម្រេច ព្រោះថានិយោជិតនោះនឹងជួបការលំបាកយ៉ាងខ្លាំងក្នុងការរស់នៅ ប្រសិនបើមិនបានបើកប្រាក់ខែ ក្នុងខណៈដែលវិវាទនោះកំពុងត្រូវបានដោះស្រាយទេនោះ។

២. ភាពចាំបាច់នៃការរក្សាការពារ ៖ ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។ [៣១]

<u>ឧទាហរណ៍</u> ៖ ករណីដែលការខូចខាតដែលមិនអាចជួសជុលបាន កំពុងកើតឡើងចំពោះម្ចាស់បំណុល ដោយសារការចុះផ្សាយជាសាធារណៈនូវអត្ថបទទស្សនាវដ្ដីដែលមានលក្ខណៈជាការបរិហាកេរ្តិ៍ ករណីដែលមានការបារម្ភអំពីគ្រោះថ្នាក់ដល់សុខភាពរបស់ម្ចាស់បំណុល ដែលបង្កឡើងដោយសម្លេងនៃការសាងសង់ ជាអាទិ៍។

## កថាភាគទី២៖ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ដើម្បីជាក់ចេញនូវដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តុលាការត្រូវពិនិត្យ និងវិនិច្ឆ័យទៅលើពាក្យសុំថាសិទ្ធិទាមទារពិតជាសិទ្ធិត្រូវរក្សាការពារ ហើយមានភាពចាំបាច់ក្នុងការរក្សាការពារ។ ដូចនេះតុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបានក្នុងករណីដែលមានបារម្ភថាម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ដោយសារការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ ម៉្យាងវិញទៀត ដោយសារច្បាប់មិនកំណត់ច្បាស់ថា ក្នុងករណីការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទនេះចាំបាច់ត្រូវឆ្លងការតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ នោះយើងអាចទាញសន្និដ្ឋានថាការទាញហេតុផលផ្ទាល់មាត់មិនមានការចាំបាច់ ដោយយោងតាមការអនុវត្តក្នុងប្រទេសជប៉ុន ក៏ជាទូទៅគេមិនសូវឃើញមានដំណាក់កាលនេះដែរ។[៣២]

ផ្ទុយទៅវិញ តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាល

---

[៣១] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា ៥៤៨ កថាខណ្ឌទី២។

[៣២]Narahara law office「民事保全の手続き」（«នីតិវិធីស្ដីពីការចាត់ចែងរក្សាការពារ»）
http://abe-narahara.com/service/komonkeiyaku/credit/536/ (បានចូលមើលចុងក្រោយ ៧ កក្កដា ២០២១)(ប៉ុន្តែគួរបញ្ជាក់ថាដោយសារតុលាការថ្នាក់ទាបតូក្យូ និងអូសាកាមានភ្នាក់ងារជំនាញខាងការចាត់ចែងរក្សាការពារនេះ នីតិវិធីទាញហេតុផលផ្ទាល់មាត់តែងតែមាន។)

បរិច្ឆេទនៃការសាកសួរដែលកូនបំណុលអាចចូលរួមបាន។ [៣៣] ដោយសារតែ ការចាត់ចែងជាបណ្តោះអាសន្ន ចំពោះការកំណត់ឋានៈជាបណ្តោះអាសន្ននេះ វាមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល ដែលអាចនាំឱ្យខូចផលប្រយោជន៍កូនបំណុលប្រសិនបើការមានការដាក់ការចាត់ចែងរក្សាការពារនេះ។ ហេតុនេះហើយបានជាច្បាប់ផ្តល់ឱកាស ឲ្យដល់កូនបំណុលក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះ។ ក៏ប៉ុន្តែ ប្រសិនបើមានស្ថានភាពពិសេសដែលនាំឲ្យពុំអាចសម្រេចគោលបំណង នៃពាក្យសុំឲ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន អាចចេញបានដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាមទារហេតុផលដោយផ្ទាល់មាត់ទេ។[៣៤] ស្ថានភាពពិសេសនៅទីនេះ គឺសំដៅដល់ការប៉ះពាល់ដល់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលខ្លាំង និងមានហានិភ័យធំដល់ម្ចាស់បំណុល។[៣៥]

<u>ឧទាហរណ៍</u> ៖ ក្នុងករណីដែលទស្សនាវដ្តីមានផ្ទុកនូវអត្ថបទបរិហារកេរ្តិ៍ និង ត្រូវចេញផ្សាយជាសាធារណៈនោះនិងមិនអាចធ្វើទៅរួចឡើយ ប្រសិនបើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់សិន។

លើសពីនេះទៀត ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ពុំមានការចាត់ចែងជាបណ្តោះអាសន្នណាមួយដែលកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវធ្វើ ដើម្បីលុបចោលការអនុវត្តការចាត់ចែង (ប្រាក់រំដោះ) នោះឡើយ ព្រោះថាគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្ន មិនមែនដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំឲ្យសងជាប្រាក់ទេ។

### **កថាភាគទី៣៖ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន**

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុលោមតាមបញ្ញត្តិដូចគ្នានឹង ការអនុវត្តរឹបអូសជាបណ្តោះអាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស។ ទោះជាយ៉ាងណាក៏ដោយ ដូចបានពន្យល់ពីខាងដើម ការចាត់ចែងជាបណ្តោះអាសន្នមួយចំនួនដែលគោលបំណងរបស់វាអាចសម្រេចបានដោយគ្រាន់តែបង្កើតឋានៈ

---

[៣៣] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី១។

[៣៤] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២។

[៣៥] កម្មវិធីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាល ផ្នែករដ្ឋប្បវេណីនៅ នៅសាលាភូមិន្ទចៅក្រម. «សំនួរដែលត្រូវបានគេសួរញឹកញាប់ ស្តីពីការចាត់ចែងរក្សាការពារ» » បោះពុម្ពខែឧសភា ឆ្នាំ២០០៩, ទំព័រ១៣។

គតិយុត្តដោយដីកាសម្រេច ហើយរង់ចាំឲ្យកូនបំណុលអនុវត្តកាតព្វកិច្ច ដោយស្ម័គ្រចិត្ត នោះមិនត្រូវការឲ្យមានការអនុវត្ត។ ដោយឡែក ការចាត់ចែងជាបណ្តោះអាសន្ន មួយចំនួនទៀត ដូចជា ការចាត់ចែងជាបណ្តោះអាសន្នដែលគ្រាន់តែបង្គាប់កូនបំណុលមិនឲ្យធ្វើសកម្មភាព អ្វីមួយ ជាដើមក៏មិនត្រូវការឲ្យមានការអនុវត្តដែរ លើកលែងតែករណីដែលកូនបំណុលបំពានករណីយកិច្ចដែលបានបង្គាប់នោះ។

## ផ្នែកទី២៖ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

### កថាភាគទី១៖ វិធីនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ដោយសារថាវិធីចាត់ចែងជាបណ្តោះអាសន្នមានច្រើន [៣៦] ដូច្នេះទើបពុំមានបញ្ញត្តិចែងឲ្យបានជាក់លាក់អំពីវិធីនៃការអនុវត្តទេ។ វិធីនៃការអនុវត្តនីមួយៗ ត្រូវអនុលោមទៅតាមវិធីដែលមានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីសម្រេចបញ្ជាប់ នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យសងជាប្រាក់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់។ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យប្រគល់អចលនវត្ថុ និងចលនវត្ថុ។[៣៧] ចំណែកឯការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យកូនបំណុលធ្វើ ឬមិនធ្វើសកម្មភាពអ្វីមួយ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តជំនួស [៣៨] និងវិធានបង្ខំដោយប្រយោល។[៣៩]

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ បើដីកាសម្រេចដែលហាមឃាត់មិនឲ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឲ្យកូនបំណុលប្រគល់វត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឲ្យប្រគល់វត្ថុនោះត្រូវបានចេញអាជ្ញាសាលា ថៃរក្សា គ្រប់គ្រងវត្ថុនោះដោយបិទលិខិតប្រកាសជាសាធារ

[៣៦] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥៤៩។

[៣៧] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥២៧។

[៣៨] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥២៧។

[៣៩] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥២៨ ។

ណៈ តាមរបៀបដែលពុំងាយបកចេញ ឬ ប្រកាសជាសាធារណៈ តាមរបៀបសមរម្យផ្សេងទៀត។[40] មានន័យថា បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្នុងនៃអាគារដែលជាកម្មវត្ថុប្រកាសនោះ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំងនៃអាគារនោះ ឬនៅកន្លែង ណាផ្សេងដែលងាយនឹងមើលឃើញ។ បើបិទប្រកាសជាសាធារណៈ នៅផ្នែកខាងក្នុងនៃអាគារដែលជាកម្មវត្ថុប្រកាសនោះ ត្រូវបិទភ្ជាប់ទៅនឹងជញ្ជាំងនៃអាគារនោះ ឬនៅកន្លែងណាផ្សេងដែលងាយនឹងមើលឃើញ។ បើបិទប្រកាសជាសាធារណៈនៅផ្នែកខាងក្រៅនៃអាគារ ឬ ប្រកាសជាសាធារណៈលើដីវិញ ក្តារប្រកាសដែលរៀបរាប់អំពីខ្លឹមសារនៃការប្រកាសជាសាធារណៈនោះ ត្រូវដំភ្ជាប់នឹងសសរឈើដោយប្រើដែកគោល ឬ ត្រូវដាក់ភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារដោយដំដែកគោល ឬ វិធីផ្សេងៗទៀតភ្ជាប់នឹងជញ្ជាំងខាងក្រៅនៃអាគារ។

**កថាភាគទី២៖ អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន**

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង៖ បើការចាត់ចែងជាបណ្តោះអាសន្នមានខ្លឹមសារជាការហាមឃាត់ការចាត់ចែងរបស់កូនបំណុល លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ នោះស្រដៀងគ្នាទៅនឹងករណីនៃការរឹបអូសជាបណ្តោះអាសន្នដែរ ការចាត់ចែងរបស់កូនបំណុលដែលធ្វើផ្ទុយនឹងការហាមឃាត់នេះ មិនអាចតតាំងជាមួយនឹងម្ចាស់បំណុល នៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ។ មានន័យថា តតិយជនដែលបានទទួលសិទ្ធិពីការចាត់ចែងនេះ មិនអាចយកលទ្ធកម្មនេះទៅតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ ហើយលទ្ធកម្មនេះនឹងត្រូវបានចាត់ទុកថាពុំមានអត្ថិភាពនៅក្នុងការអនុវត្តដោយបង្ខំនៅពេលបន្ទាប់។

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់៖ ក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្តោះអាសន្នណាដែលមានការប្រកាសជាសាធារណៈដូចបានរៀបរាប់ខាងលើ។ បើមានការផ្ទេរការកាន់កាប់ដោយផ្ទុយនឹងការហាមឃាត់នេះ ការផ្ទេរនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ។ ហេតុនេះហើយ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុបានដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្តី។[41] នៅក្នុងបណ្តឹងទាមទារឲ្យប្រគល់វត្ថុប្រសិនបើបណ្តឹងនោះធ្វើឡើង ដោយយកអ្នកកាន់កាប់នៅពេលបណ្តឹង

[40] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥៧១ កថាខណ្ឌទី ១។

[41] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៧១ កថាខណ្ឌទី ២ វាក្យខណ្ឌទី១។

កំពុងត្រូវបានចាត់ការធ្វើជាចុងចម្លើយអានុភាពនៃសាលក្រមនឹងមានទៅលើបុគ្គលដែលទទួលបន្តនូវការកាន់កាប់ នៅក្រោយពេលដែលបណ្ដឹងត្រូវបានចាត់ការ បើទោះបីជាមានការផ្ទេរការកាន់កាប់ក៏ដោយ។ [៤២] ក៏ប៉ុន្តែអានុភាពនៃសាលក្រម មិនត្រូវមានទៅលើអ្នកកាន់កាប់ដែលមិនបានទទួលបន្តនូវសិទ្ធិកាន់កាប់ នៅពេលដែលបណ្ដឹងកំពុងត្រូវបានចាត់ការនោះទេ។

ឧទាហរណ៍ ៖ ដូចជាអ្នកកាន់កាប់ខុសច្បាប់។

ម្យ៉ាងទៀត នៅក្នុងករណីដែលកម្មវត្ថុនោះគឺជាចលនវត្ថុ នោះក៏អាចនឹងកើតមាននូវករណីនៃលទ្ធកម្មដោយសុខចិត្តបានដែរ។ ហេតុនេះហើយ ច្បាប់អនុញ្ញាតឲ្យបុគ្គលដែលមានបំណងចង់ដាក់ពាក្យបណ្ដឹងទាមទារឲ្យប្រគល់វត្ថុ ឬ បុគ្គលដែលបានដាក់ពាក្យបណ្ដឹងនោះហើយ អាចកំណត់ទំនាក់ទំនងនៃការកាន់កាប់បច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ ការពង្រីកអានុភាពនៃសាលក្រមតាមវិធីនេះ ត្រូវបានកម្រិតត្រឹមតែករណីដែលអ្នកកាន់កាប់វត្ថុនោះ ដឹងថាមានការចាត់ចែងជាបណ្ដោះអាសន្នប៉ុណ្ណោះ។ [៤៣] មូលហេតុនៃការកំណត់បែបនេះ ព្រោះថា ទោះបីជាក្នុងករណីនៃលទ្ធកម្មនៃការកាន់កាប់មិនមែនជាការទទួលបន្តក៏ដោយ ក៏អ្នកកាន់កាប់ដោយទុច្ចរិត មិនត្រូវទទួលការការពារដែរ។ គួរបញ្ជាក់ថា ជនដែលកាន់កាប់ ដែលចាប់ផ្ដើមការកាន់កាប់ ក្រោយពេលដែលការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានប្រកាសជាសាធារណៈ ត្រូវសន្មត់ថា ជាអ្នកកាន់កាប់ដោយទុច្ចរិត ហេតុនេះហើយ ដើម្បីតទល់នឹងការសន្មត់នេះ អ្នកកាន់កាប់ត្រូវបញ្ជាក់អំពីភាពសុចរិតនៃការកាន់កាប់របស់ខ្លួន។ ក្នុងករណីដែលអ្នកកាន់កាប់វត្ថុដែលពាក់ព័ន្ធ ដោយមានសិទ្ធិដែលនាំឲ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់ ដែលអាចតតាំងជាមួយនឹងម្ចាស់បំណុល ដូចជា ករណីដែលជននេះមានសិទ្ធិជួល ដែលអាចតតាំងជាមួយនឹងម្ចាស់បំណុលបាន ឬ ក្នុងករណីដែលអ្នកកាន់កាប់ មិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ហើយមិនមែនជាអ្នកទទួលបន្តនូវការកាន់កាប់ពីកូនបំណុល ដូចជាករណីដែលជននោះកាន់កាប់វត្ថុដែលពាក់ព័ន្ធដោយមិនបានដឹងអំពីការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ព្រោះសេចក្ដីប្រកាសជាសាធារណៈបានបកបាត់ ជាដើម។ អ្នកកាន់កាប់នេះ អាចអះអាង អំពីស្ថានភាពនេះ ដោយដាក់ពាក្យតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត។ [៤៤]

---

[៤២] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ១៩៨ ចំណុច គ និងមាត្រា ៣៥១ កថាខណ្ឌទី១ចំណុច គ ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ។

[៤៣] មាត្រា ៥៧១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២។

[៤៤] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៣៦២។

ការចាត់ចែងជាបណ្ដោះអាសន្នដោយឡែកណា ដែលរារាំងអានុភាព នៃការចាត់ចែងជាបណ្ដោះអាសន្ន ឬដែលផ្អាកការចាត់ចែងជាបណ្ដោះអាសន្ន មិនត្រូវបានអនុញ្ញាតទេ។ ដើម្បីចាកចេញនូវការចាត់ចែងជាបណ្ដោះអាសន្ន កូនបំណុលត្រូវដាក់ពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ចំណែកតតិយជន ត្រូវដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន ឬ ដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយករណីដែលមាន ការចាត់ចែងជាបណ្ដោះអាសន្នច្រើនលើ កម្មវត្ថុតែមួយ មិនត្រូវបានហាមឃាត់ទេ ប្រសិនបើខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នទាំងនោះ មិនមានខ្លឹមសារផ្ទុយគ្នា។

ឧទាហរណ៍៖ ករណីដែលការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង និងការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការផ្ទេរការកាន់កាប់ ត្រូវបានអនុវត្តចំពោះអចលនវត្ថុតែមួយ។

## ផ្នែកទី៣៖ ការតវ៉ាពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

### កថាភាគទី១៖ ឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

#### ក. ការតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ចំពោះដីកាសម្រេចរក្សាការពារ មិនអាចប្ដឹងជំទាស់ភ្លាមបានទេ ប៉ុន្តែអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចនោះបាន។[៤៥] ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្ដល់ឲ្យកូន បំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុន ក្នុងការសុំឲ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃដីកាសម្រេចការចាត់ចែងជាបណ្ដោះអាសន្ន មិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែល ដែលចំណុចនេះស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿននៅក្នុងនីតិវិធីនៃការដាស់តឿនដែរ។ ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់ លុបចោលដីកាសម្រេចលើកចោលពាក្យស្នើសុំតវ៉ាចំពោះដីកាសម្រេចនេះត្រូវដាក់ទៅតុលាការនៃបណ្ដឹងជំទាស់នោះដែរ។

ពាក្យសុំតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ដោយពុំមានការកំណត់អំឡុងពេល ពាក្យសុំតវ៉ា អាចដាក់នៅពេលណាក៏បានឲ្យតែដីកាចាត់ចែងបណ្ដោះអាសន្ននៅមានសុពលភាព។ ការដាក់ពាក្យសុំតវ៉ា មិនធ្វើឲ្យអានុភាពអនុវត្តនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្ដីសម្រេច

[៤៥] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥០។

បណ្តោះអាសន្នដោយឡែក ដែលបង្គាប់ឲ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការតុបតែងការអនុវត្ត។ សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណី ដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ។

នៅក្នុងការវិនិច្ឆ័យក្នុងការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។[៤៦] គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ទៅឲ្យភាគីជាពិសេសកូនបំណុល នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី។ ប៉ុន្តែយ៉ាងណាក៏ដោយ វាមិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាអោយបាននូវកាលបរិច្ឆេទ ដែលភាគីទាំងសងខាងអាចចូលរួមបានតែម្តងក៏ជាការគ្រប់គ្រាន់ដែរ។ ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាជាគោលការណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ។ [៤៧] ទោះបីជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច តុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួននៅពេលណាក៏បាន ក៏នៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្តល់ឱកាសឲ្យភាគីក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យ ទៅតុលាការឲ្យបានគ្រប់គ្រាន់។ ប៉ុន្តែ ប្រសិនបើការវិនិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឲ្យបានគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនឹងនីតិវិធីបណ្តឹងដែរ។[៤៨]

ប្រសិនបើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះ។ រីឯតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ។ ករណីនេះរួមបញ្ចូល ករណីដូចជាល័ក្ខខណ្ឌ ដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬ ការដាក់បន្ថែមនូវប្រាតិភោគនៅក្នុងអំឡុងពេលណាមួយ។ ដីកាសម្រេចទាំងនេះត្រូវបញ្ជូនទៅភាគី ដែលអនុញ្ញាតឱ្យធ្វើការតវ៉ា។

---

[៤៦] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥២។

[៤៧] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥៥ កថាខណ្ឌទី១។

[៤៨] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥៥៣ កថាខណ្ឌទី២។

### ខ. ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ក្រៅពីការលុបចោលដោយសារការតវ៉ា ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នអាចត្រូវបានលុបចោលនៅក្នុងករណីពីរទៀត ដែលមាននីតិវិធីដោយឡែកពីគ្នា គឺការលុបចោលដោយសារការមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី និង ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព។

ការលុបចោលដោយសារ ការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីតុលាការ ដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដីដោយឲ្យដាក់ឯកសារដែលបញ្ជាក់ពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យតាមពាក្យសុំរបស់កូនបំណុល។ ការបង្គាប់នេះហៅថា ការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹង។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំអោយម្ចាស់បំណុលទៅទទួលលិខិតអនុវត្តសម្រាប់ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះនឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នឲ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹង អាចចេញបានដោយពុំមានល័ក្ខខណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី មិនត្រូវតិចជាង២សប្ដាហ៍ទេ។[៤៩]

ប្រសិនបើម្ចាស់បំណុលមិនដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដី នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការបង្គាប់ឲ្យដាក់ពាក្យបណ្ដឹងទេ តុលាការត្រូវលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នតាមពាក្យសុំរបស់កូនបំណុល។ ម្យ៉ាងទៀត ប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយ ពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នោះត្រូវចាត់ទុកថា ឯកសារនេះមិនបានដាក់ឡើយ ហើយការនោះក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលផងដែរ។

ការលុបចោលដោយសារការផ្លាស់ប្ដូរស្ថានភាព បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្ដូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដីអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះ។ ការផ្លាស់ប្ដូរស្ថានភាពនេះ ត្រូវបានបែងចែកជាពីរប្រភេទ ។

---

[៤៩] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ ,មាត្រា ៥៦០។

ប្រភេទទីមួយ គឺករណីដែលក្រោយពេលចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន មានកើតឡើងនូវអង្គហេតុថ្មី ដែលធ្វើឲ្យដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះមានភាពមិនត្រឹមត្រូវ។

ប្រភេទទីពីរ គឺករណីដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឲ្យដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬ អាចធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ទោះបីជាអង្គហេតុនោះ បានកើតឡើងនៅពេលចេញដីកាសម្រេចរក្សាការពារក៏ដោយ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការផ្លាស់ប្ដូរស្ថានភាពនោះ។

**គ. បណ្ដឹងជំទាស់**

ដូចដែរបានរៀបរាប់ខាងលើ ចំពោះដីកាចាត់ចែងជាបណ្ដោះអាសន្ន មិនអាចប្ដឹងជំទាស់បានទេ។ ក៏ប៉ុន្តែ ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ ពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចប្ដឹងជំទាស់បាន។

ដីកាសម្រេចដែលទទួលស្គាល់ផ្លាស់ប្ដូរ ឬ លុបចោលការសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយផ្អែកលើពាក្យសុំតវ៉ា និង ដីកាសម្រេចដែលលើកចោលពាក្យសុំទាមទារឲ្យលុបចោល ឬ ដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយ ផ្អែកលើពាក្យសុំទាមទារឲ្យលុបចោល សុទ្ធសឹងជាមុខសញ្ញានៃការប្ដឹងជំទាស់។ អំឡុងពេលនៃការប្ដឹងជំទាស់ គឺ ២សប្ដាហ៍ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន។

ក្នុងករណី ដែលតុលាការនៃបណ្ដឹងជំទាស់ ចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នជាលើកទីមួយ បណ្ដឹងជំទាស់មិនអាចធ្វើបានទេ ចំពោះដីកាសម្រេចនេះ ព្រោះមានការបកស្រាយថាដីកាសម្រេចនេះ បានបំពេញល័ក្ខខណ្ឌនៃប្រព័ន្ធនៃការជម្រះក្ដីពីរថ្នាក់រួចហើយ។ ផ្ទុយទៅវិញក្នុងករណី ដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន និង លើកចោលពាក្យសុំតវ៉ា ឬ ពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះ នៅក្នុងបណ្ដឹងអង្គសេចក្ដី ដែលកំពុងត្រូវបានចាត់ការនៅសាលាឧទ្ធរណ៍ នោះបណ្ដឹងជំទាស់អាចធ្វើទៅតុលាការកំពូលបាន ដើម្បីធានាឲ្យបាននូវប្រព័ន្ធនៃការជម្រះក្ដីពីរថ្នាក់។

**កថាភាគទី២៖ អានុភាពនៃការលុបចោលដីកាចាត់ចែងជាបណ្ដោះអាសន្ន**

នៅក្នុងករណីដែលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលបានចេញម្ដងហើយ ត្រូវលុបចោលវិញ ដោយសារពាក្យសុំតវ៉ា ពាក្យសុំទាមទារឲ្យលុបចោល ឬ បណ្ដឹងជំទាស់ ប្រសិនបើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬការបង់ប្រាក់ ឬកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងវត្ថុដោយផ្អែកលើដីកាសម្រេចចាត់ចែងជា

បណ្តោះអាសន្ននោះ តុលាការអាចបង្គាប់ឲ្យម្ចាស់បំណុល បង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រងនៅក្នុងដីកាសម្រេចលុបចោលនោះបានតាមពាក្យសុំរបស់កូនបំណុល។ [៥០] មូលហេតុនៃការកំណត់បែបនេះ ព្រោះថាប្រសិនបើដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលផ្លាស់ប្តូរនូវស្ថានភាពដើមត្រូវបានអនុវត្តហើយ ស្ថានភាពដើមនោះ មិនអាចធ្វើបដិទាន [៥១] បានវិញឡើយគ្រាន់តែ លុបចោលដីកាសម្រេចចាត់ចែងដោយបណ្តោះអាសន្ននោះទេ។ ហេតុនេះហើយ តុលាការត្រូវតែអាចបង្គាប់ឲ្យធ្វើបដិទាននូវស្ថានភាពដើម នៅក្នុងដីកាសម្រេចលុបចោល។ បណ្តឹងជំទាស់អាចធ្វើឡើងដោយឯករាជ្យបានចំពោះដីកាសម្រេចទាំងនេះ។[៥២]

**កថាភាគទី៣៖ ការលុបចោលការចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស**

ស្រដៀងគ្នាទៅនឹងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែរ ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស។ មានន័យថា តុលាការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តាមពាក្យស្នើសុំរបស់កូនបំណុលបានប្រសិនបើមានការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬមានស្ថានភាពពិសេសផ្សេងទៀត។ [៥៣] តុលាការដែលមានសមត្ថកិច្ច គឺតុលាការដែលបានចេញដីកាសម្រេច ចាត់ចែងជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តី។

ករណីដែលដីកាសម្រេចជាបណ្តោះអាសន្ន អាចនឹងត្រូវបានលុបចោលដោយសារស្ថានភាពពិសេសត្រូវបានបែកចែកជាពីរ។ ករណីទីមួយ គឺករណីដែលគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នអាចសម្រេចបានដោយការសងជាប្រាក់ទៅឲ្យម្ចាស់បំណុល។ ទោះបីជាទូទៅ ការសងជាប្រាក់សុទ្ធសាធ មិនអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្ននោះ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសង

---

[៥០] ក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា៥៥៥ មាត្រា៥៦០កថាខណ្ឌទី មាត្រា៥៦១កថាខណ្ឌទី៣។

[៥១] បដិទានការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ ទំព័រ១២ នៃសន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[៥២] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុចខ និងចំណុចគ។

[៥៣] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦, មាត្រា ៥៥៩ កថាខណ្ឌទី១។

ជាប្រាក់ក៏ដោយ ក៏ប៉ុន្តែក្នុងករណីដែលការចាត់ចែងជាបណ្ដោះអាសន្ននោះ មានមូលដ្ឋានជាសិទ្ធិទាមទារឲ្យសងជាប្រាក់ ឬ ករណីដែលមានសិទ្ធិទាមទារឲ្យសងជាប្រាក់ស្ថិតនៅពីក្រោយការចាត់ចែងជាបណ្ដោះអាសន្ននោះ ប្រសិនបើការសងជាប្រាក់ នឹងធ្វើឲ្យសម្រេចយ៉ាងជាក់ស្ដែងនូវសិទ្ធិដែលត្រូវបានរក្សាការពារ នោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន អាចធ្វើបានដោយតម្រូវឲ្យការដាក់ប្រាតិភោគ។

ឧទាហរណ៍៖ ដូចជា ករណីនៃការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងទ្រព្យសម្បត្តិរបស់អ្នកដែលបានទទួលផលប្រយោជន៍ ដើម្បីរក្សាការពារនូវសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឲ្យលុបចោលនូវអំពើដែលនាំឲ្យផលប្រយោជន៍ ដែលប្រព្រឹត្តឡើងដោយកូនបំណុលជាដើម។

ករណីទីពីរ គឺករណី បើគិតពីសមធម៌រវាងភាគីទាំងពីរ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរជាងការខូចខាតដែលកើតឡើងជាធម្មតាចំពោះកូនបំណុលដែលមកពី ការចាត់ចែង ជាបណ្ដោះអាសន្នមានទំហំធំធេងខ្លាំងជាង ការខូចខាតចំពោះម្ចាស់បំណុលដែលបណ្ដាលមកពី ការមិនអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះផ្ទុយនឹងគោលការណ៍សមធម៌ហើយ។

ឧទាហរណ៍៖ ករណីដែលការចាត់ចែងជាបណ្ដោះអាសន្ន ដោយការដែលអាជ្ញាសាលាទៅថែរក្សាគ្រប់គ្រងចលនវត្ថុ ដែលកូនបំណុលកំពុងលក់ដូរ ធ្វើឲ្យកូនបំណុលនោះមិនអាចធ្វើអាជីវកម្ម ឬ មានការពិបាកយ៉ាងខ្លាំងក្នុងការបន្តអាជីវកម្មទៅមុខទៀត។ ចំពោះស្ថានភាពពិសេសទាំងនេះកូនបំណុលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង។[៥៤]

បញ្ញត្តិទាក់ទងទៅនឹងការសម្រេចសេចក្ដី អំពីការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្ដីអំពីពាក្យសុំឲ្យលុបចោលដោយសារស្ថានភាពពិសេសនោះ ។ មានន័យថា បញ្ញត្តិស្ដីពីការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន រួមមាន៖[៥៥]

---

[៥៤] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , បញ្ញត្តិចាប់ពីមាត្រា ៤២៨ និងមាត្រា ៥៥៩ កថាខណ្ឌទី២។

[៥៥] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៦០ កថាខណ្ឌទី១ និងមាត្រា ៥៥១។

ក. ការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរនៅកាលបរិច្ឆេទដែលភាគីទាំងពីរអាចចូលរួម[៥៦]បាន។

ខ. ការបញ្ចប់ការវិនិច្ឆ័យ[៥៧]

គ. អានុភាពនៃការសម្រេចដែលលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវយកមកអនុវត្ត ដូចគ្នា ចំពោះការលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារស្ថានភាពពិសេសនេះ។ ជាង នេះទៅទៀត ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន ក៏អាចចេញដែរ នៅក្នុងករណីនេះ។ ដីកាសម្រេចលុបចោលនេះ ត្រូវចេញដោយដាក់ល័ក្ខខណ្ឌតម្រូវឲ្យកូនបំណុលដាក់ប្រាតិភោគ។ ដីកាសម្រេចអំពីពាក្យសុំឲ្យលុបចោល ត្រូវ បញ្ជូនទៅឲ្យភាគី ហើយចំពោះដីកាសម្រេចនេះ អាចប្ដឹងជំទាស់បាន។[៥៨]

[៥៦] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥២។

[៥៧] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥៣។

[៥៨] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦ , មាត្រា ៥៥៦ មាត្រា ៥៥៥ និងមាត្រា ៥៥៩ កថាខណ្ឌទី៣ និង មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុចក។

# ជំពូកទី៣

# លក្ខណៈខុសគ្នានៃការចាត់ចែងជាបណ្តោះអាសន្នរវាងប្រទេសកម្ពុជា-ជប៉ុន

ដូចដែលបានរៀបរាប់ខាងលើ សញ្ញាណទូទៅ និងនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសកម្ពុជា គឺវាមិនមានភាពខុសប្លែកប៉ុន្មានទៅអ្វីដែលមានចែងក្នុងច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណីនៃប្រទេសជប៉ុនឡើយ។ ជាក់ស្តែង ចំពោះប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្នដូចជា ការចាត់ចែងជាបណ្តោះអាសន្នចំពោះឋានៈជាបណ្តោះអាសន្ន ទោះបីជាក្នុងច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណី នៃប្រទេសជប៉ុនមិនបានចែងកំណត់ច្បាស់លាស់ក្តី ក៏គេឃើញថាក្នុងការអនុវត្តករណីជាក់ស្តែងមួយចំនួន គឺវាមានលក្ខណៈប្រហាក់ប្រហែលនឹងការចាត់ចែងជាបណ្តោះអាសន្ននេះដែរ។ ប៉ុន្តែដោយសារប្រទេសកម្ពុជានៅតែកំពុងស្ថិតក្រោមជំនួយពីអ្នកជំនាញបរទេស ជាហេតុនាំឱ្យប្រព័ន្ធច្បាប់ប្រទេសកម្ពុជាមិនទាន់មានភាពពេញលេញនៅឡើយទេ។[៥៩] របបទាក់ទងនឹងការចាត់ចែងជាបណ្តោះអាសន្នក៏បែបនេះដែរ គឺវានៅតែមានបញ្ហាមួយចំនួនដែលនឹងលើកឡើងខាងក្រោមនេះ។

## ផ្នែកទី១៖ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសជប៉ុន

### កថាភាគទី១៖ ការដាក់ប្រាតិភោគ តាមដីកាសម្រេច ចាត់ចែងជាបណ្តោះអាសន្នក្នុងប្រទេសជប៉ុន

យោងតាមមាត្រា៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារអាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគ។ ចំណុចនេះ គឺវាមានលក្ខណៈដូចគ្នាទៅនឹងច្បាប់ប្រទេសជប៉ុនដែរ ចំពោះការដាក់ ឬ មិនដាក់ប្រាតិភោគនេះជាឆន្ទានុសិទ្ធិនៃចៅក្រម។ ដូចនេះ វានាំឱ្យមានចម្ងល់ចោទសួរថា ចៅក្រមធ្វើការសម្រេចដាក់ ឬ មិនដាក់ប្រាតិភោគដោយផ្អែកលើមូលដ្ឋានអ្វី។ មុននឹងសិក្សាពីមូលដ្ឋាននៃការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននេះ យើងនឹងធ្វើការសិក្សាទៅលើមូលហេតុដែលនាំឱ្យមានការដាក់ប្រាតិភោគជាមុនសិន។

[៥៩] Matsuo 「カンボジア司法アクセス」(« ប្រព័ន្ធយុត្តាធិការនៅប្រទេសកម្ពុជា»), ផ្នែកស្រាវជ្រាវនីតិសាស្ត្រនៃសកលវិទ្យាល័យខេអុនៃប្រទេសជប៉ុន ថ្ងៃទី៨ មិនា ២០១៣។

### ក. មូលហេតុនៃការដាក់ប្រាតិភោគ

មូលហេតុដែលច្បាប់កំណត់ឱ្យមានការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារកត្តាពីរ។[៦០]

កត្តាទីមួយ គឺ ដើម្បីធានាដល់សំណងខូចខាតទៅលើកូនបំណុល។ សំណងខូចខាតនេះ អាចកើតមានឡើងដោយសារការស្នើសុំ ឬ ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននេះមានទម្រង់ខុសច្បាប់។ ដោយសាររបបការចាត់ចែងជាបណ្ដោះអាសន្នជានីតិវិធីដែលមានលក្ខណៈជាបណ្ដោះអាសន្ន ហើយត្រូវធ្វើការសម្រេចចេញដីកាក្នុងរយៈពេលខ្លី និង ឆាប់រហ័សដើម្បីធានាដល់ការអនុវត្តសិទ្ធិនៃម្ចាស់បំណុល។ ហេតុនេះហើយ ក្នុងដំណាក់កាលនៃម្ចាស់បំណុលដាក់ពាក្យស្នើសុំ ដែលក្នុងពាក្យស្នើសុំនោះត្រូវមានលើកឡើងនូវភស្តុតាងមកបញ្ជាក់ពីសិទ្ធិទាមទារ និងភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្ន ដែលត្រូវបានទទួលស្គាល់ថាជាសិទ្ធិដែលត្រូវការពារ ដោយឈានដល់ការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះ ។ ប៉ុន្តែ មានករណីមួយចំនួនកើតឡើង ដោយទោះបីជា ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នបានចេញហើយក្ដី នៅពេលនីតិវិធីនៃបណ្ដឹងបានបន្តរហូតដល់ចេញសាលដីកាចុងក្រោយ ដោយគេវិនិច្ឆ័យឃើញថា សិទ្ធិនៃការចាត់ចែងជាបណ្ដោះអាសន្ន គឺមិនមាននោះទេ។ ដូចនេះ គេអាចនិយាយបានថា ការស្នើសុំចាត់ចែងជាបណ្ដោះអាសន្ននេះ មិនបានបំពេញនូវលក្ខខណ្ឌនៃ ការចាត់ចែងជាបណ្ដោះអាសន្នឡើយ។ ក្នុងការបកស្រាយច្បាប់នៃប្រទេសជប៉ុន ភាពកង្វះខាតនៃលក្ខខណ្ឌ ជាគោលការណ៍ គឺការស្នើសុំដែលមានទម្រង់ខុសច្បាប់។[៦១] ដូចនេះ បើសាលដីកាចុងក្រោយបង្ហាញឱ្យឃើញថា ដើមចោទ ឬ ម្ចាស់បំណុលចាញ់ក្ដី ដែលបង្ហាញឱ្យឃើញថា សិទ្ធិនៃការទាមទារចាត់ចែងជាបណ្ដោះអាសន្ននោះក៏មិនមានដូចគ្នា នោះការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នទៅលើកូន

---

៦០ Mitsuho law office「民事保全における担保の基礎について」( «មូលដ្ឋាននៃការដាក់ប្រាតិភោគក្នុងករណីការចាត់ចែងរក្សាការពារ»)
https://www.mclaw.jp/kigyohomu/26681/?fbclid=IwAR0awbzcb316p7uRbiSpp1uPHuIlL7p412X9TMdALQfKWRzWYX_Qa7kV9vE (បានចូលមើលចុងក្រោយ៖ ០៨ កក្កដា ២០២១)។

៦១ Mizuho law office,「違法な保全の申立や執行による損害賠償責任の基本」(«សំណងខូចខាតដោយសារការស្នើសុំ ឬការអនុវត្តការចាត់ចែងរក្សាការពារដែលមានទម្រង់ខុសច្បាប់» ) ចុះផ្សាយ១៧ មិថុនា ២០១៥ https://www.mc-law.jp/kigyohomu/19391/ (បានចូលមើលចុងក្រោយ៖ ០៨ កក្កដា ២០២១)។

បំណុលដែលធ្វើមុនពេលសាលដីកាបានចូលជាស្ថាពរនោះ អាចនាំឱ្យមានការខូចខាតប៉ះពាល់ដល់កូនបំណុល ដែលទាមទារឱ្យម្ចាស់បំណុលជាអ្នកទទួលខុសត្រូវលើសំណងខូចខាតនោះ។

កត្តាទីពីរ គឺ ការទប់ស្កាត់លើការរំលោភលើសិទ្ធិស្នើសុំចាត់ចែងជាបណ្ដោះអាសន្ន។ ដោយសាររបបនៃការចាត់ចែងជាបណ្ដោះអាសន្នមានភាពឆាប់រហ័ស និងធ្វើដោយសម្ងាត់ ហើយធានាដល់ការអនុវត្តសិទ្ធិដល់ម្ចាស់បំណុល ជាហេតុនាំឱ្យម្ចាស់បំណុលធ្វើការដាក់ពាក្យស្នើសុំការធ្វើការចាត់ចែងជាបណ្ដោះអាសន្ននេះ។ ប៉ុន្តែ មានករណីមួយចំនួនដែលម្ចាស់បំណុលមានចេតនាក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនដោយរំលោភបំពានលើសិទ្ធិ។ ដូចនេះ ការដាក់ប្រាតិភោគអាចទប់ស្កាត់ដល់ការប្រើប្រាស់សិទ្ធិបំពានលើការសុំដីកាសម្រេចការចាត់ចែងជាបណ្ដោះអាសន្ន។ [៦២]

### ខ.មូលដ្ឋាននៃការដាក់ ឬ មិនដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ការដាក់ ឬ មិនដាក់ប្រាតិភោគនេះមានបីទម្រង់។ ទម្រង់ទាំងនោះរួម ការបង្គាប់ឱ្យដាក់ប្រាតិភោគស្របពេលចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ការបញ្ជាក់ក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយការដាក់ប្រាតិភោគ គឺជាលក្ខខណ្ឌនៃការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន និងការមិនដាក់ប្រាតិភោគតាម ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នឡើយ។ [៦៣] បើមើលទៅលើការអនុវត្តជាក់ស្ដែងក្នុងប្រទេសជប៉ុន ភាគច្រើនឱ្យតែមានការដាក់ចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាគោលការណ៍ គឺមានការដាក់ប្រាតិភោគ។ រីឯការមិនដាក់ប្រាតិភោគនេះ គឺកម្រកើតឡើងដោយវាគ្រាន់តែជាករណីពិសេសក្នុងការអនុវត្តរបស់តុលាការប៉ុណ្ណោះ ដែលគេអនុវត្តតាមយុត្តិសាស្ត្រកន្លងមក។ ករណីទីមួយដែលមិនបង្គាប់ឱ្យដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននេះ ដោយសារចំនួនទឹកប្រាក់នៃការដាក់ប្រាតិភោគមានភាពតិច

[៦២] Yamamoto Kazuhiko, 「民事保全」(*«ការចាត់ចែងរក្សាការពារ»* ) បោះពុម្ពដោយ Nipon Hyoron sha co,Ltd,ឆ្នាំ២០១៤ ទំព័រ ៥៤។

[៦៣] ការិយាល័យមេធាវីមីស៊ឺហ្ស «មូលដ្ឋាននៃការដាក់ប្រាតិភោគក្នុងករណីការចាត់ចែងរក្សាការពារ» https://www.mclaw.jp/kigyohomu/26681/?fbclid=IwAR0awbzcb316p7uRbiSpp1uPHuIlL7p412X9TMdALQfKWRzWYX_Qa7kV9vE (បានចូលមើលចុងក្រោយ៖ ០៨ កក្កដា ២០២១)។

តួចពេក ដែលជានាំឱ្យមិនមានភាពចាំបាច់ក្នុងការដាក់ប្រាតិភោគ។[៦៤] រីឯករណីទីពីរ គឺម្ចាស់បំណុលដែលជាដើមបណ្ដឹងពិតជាមានភាពលំបាកខាងសេដ្ឋកិច្ចដែលជាមូលហេតុនាំឱ្យមានភាពចាំបាច់ក្នុងការចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន។ ចំនុចនេះ មានឧទាហរណ៍ជាក់ស្ដែងពីរដែលគេយកមកអនុវត្តក្នុងប្រទេសជប៉ុន។

ឧទាហរណ៍៖ លោក «ក» បានជួលផ្ទះទៅឱ្យលោក «ខ»។ ប៉ុន្តែទោះបីជាលោក «ក» បានដាស់តឿនលោក «ខ» ជាច្រើនដងក្ដី ក៏លោក «ឡ» បានពន្យារពេលមិនព្រមបង់ថ្លៃជួលផ្ទះទៅឱ្យលោក «ក» ជាច្រើនខែ ក៏លោក «ក» សម្រេចចិត្តប្ដឹងទាមទារឱ្យលោក «ខ» ប្រគល់ផ្ទះនោះមកវិញដោយអនុវត្តដោយបង្ខំ និងសងនូវប្រាក់ឈ្នួលដែលជំពាក់ទាំងប៉ុន្មានមកវិញ។

ក្នុងករណីខាងលើនេះលោក «ក» ដោយមានភាពបារម្ភថា ខ្លួនមានភាពពិបាក ក្នុងការអនុវត្តសិទ្ធិទាមទារប្រាក់ឈ្នួលពីលោក «ខ» នោះលោក «ក» អាចដាក់ពាក្យសុំធ្វើការចាត់ចែងជាបណ្ដោះអាសន្ន ដោយសំអាងពី វិបត្តិសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីក្លាយជាល័ក្ខខណ្ឌនៃភាពចាំបាច់នៃការការពារក្នុងការចាត់ចែងជាបណ្ដោះអាសន្ន។ ដោយសារលោក «ក» ពិតជាដែលជាម្ចាស់បំណុលពិតជាមានជីវភាពលំបាកដោយមូលហេតុនៃការមិនបង់ប្រាក់ឈ្នួលពីលោក «ខ» ពិតប្រាកដមែន ទើបតុលាការធ្វើការពិចារណា និងសម្រេចចិត្តមិនបង្គាប់ឱ្យលោក «ក» ធ្វើការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នទេ។

ឧទាហរណ៍មួយទៀត៖ ទាក់ទងនឹងករណីគ្រោះថ្នាក់ចរាចរណ៍។ គឺលោក «ច» បើរថយន្តមិនប្រុងប្រយ័ត្នទៅបុកលោក «ឆ» ដែលជិះម៉ូតូនៅពីមុខ ដោយបង្កឱ្យមានលោក «ឆ» មានរបួសធ្ងន់។ នៅក្នុងករណីនេះការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ដែលបង្គាប់ឱ្យកូនបំណុលដែលជាលោក «ច» ធ្វើការបង់សំណងបណ្ដោះអាសន្នដល់ជនរងគ្រោះឬម្ចាស់បំណុលរូបលោក «ឆ» ដែលប្ដឹងទាមទារសំណង ខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍នោះ។ ដូចនេះ ចៅក្រមអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគបាន។

ពីព្រោះ ក្នុងឧទាហរណ៍ខាងលើ មូលហេតុ នៃភាពចាំបាច់នៃការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន គឺថាម្ចាស់បំណុលមិនអាចរស់នៅបានទេប្រសិនបើគ្មានប្រាក់ខែ ឬសំណងជាបណ្ដោះអាសន្ននោះ ហើយការចេញដីកានេះ គឺចាំបាច់ណាស់ ដើម្បីជៀសវាងនូវការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើត

[៦៤] ហ្វូជីហ្វារ៉ា ហ៊ីរ៉ុមីឈិ,សៀវភៅស្ដីអំពី «ការដោះស្រាយបណ្ដឹងទាមទារការរក្សាការពារនៅក្នុងតុលាការអ៊ូសាកាបច្ចុប្បន្ន» ទំព័រ៥៦។

ឡើងដល់ម្ចាស់បំណុល។ ក្នុងករណីទាំងនេះ ការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ គឺមិនត្រូវនឹងហេតុផលខាងលើទេ ជាហេតុផល ដែលគាំទ្រនូវភាពចាំបាច់នៃដីកាសម្រេចចាត់ចែងរក្សាការពារ។ ដូច្នេះហើយ នៅប្រទេសជប៉ុន តុលាការតែងចេញនូវដីកាសម្រេចចាត់ចែងរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យដាក់ប្រាតិភោគនោះទេក្នុងករណីទាំងអស់នេះ។[៦៥]

**កថាភាគទី២៖ អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**

នៅក្នុងច្បាប់ស្ដីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីនៃប្រទេសជប៉ុនបានបញ្ជាក់ពីអានុភាពមិនផ្ដាច់មុខនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នលើការហាមឃាត់ការចាត់ចែង។[៦៦] មានន័យថា នៅពេលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលើការហាមឃាត់ការចាត់ចែងលើអចលនវត្ថុណាមួយនោះគេនឹងធ្វើការអនុវត្តដោយកំណត់បញ្ជាក់លើ អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះថា «ការចាត់ចែងជាបណ្ដោះអាសន្នលើការហាមឃាត់ការចាត់ចែង» ទៅក្នុងសៀវភៅចុះបញ្ជីក៏ពិតមែន ក្រោយពីបានកំណត់បញ្ជាក់រួចរាល់ ក៏កូនបំណុលអាចធ្វើការផ្ទេរនូវអចលនវត្ថុនោះទៅតតិយជន។

<u>ឧទាហរណ៍</u>៖ លោក "ក" ប្ដឹងលោក "ខ" ឱ្យប្រគល់របស់ ដោយបានធ្វើការស្នើសុំធ្វើការចាត់ចែងជាបណ្ដោះអាសន្នលើអចលនវត្ថុដែលជាដីរបស់លោក "ខ" ។ បន្ទាប់មកលោក "ខ" ក៏បានលក់ដីនោះទៅឱ្យលោក "គ" ។ ហើយ លោក "ក" ឈ្នះក្ដី ហើយសាលក្រមចូលជាស្ថាពរ។ នោះ នៅពេលដែលលោក "ក" មានបំណងដាក់ពាក្យសុំអនុវត្តដោយបង្ខំ ទោះបីជាដីនោះត្រូវបានចុះបញ្ជីក្រោមឈ្មោះលោក "គ" ក្ដី ក៏លោក "ក" អាចធ្វើការចាត់ចែងទៅលើដីនោះបានដែរ។ លើសពីនេះទៀត អានុភាពនៃសាលក្រមចំពោះចុងចម្លើយ អាចបន្តរហូតដល់សន្តតិជន។

ដូចនេះ គេទទួលស្គាល់នូវអានុភាពនៃការផ្ទេរអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងការចាត់ចែងជាបណ្ដោះអាសន្ននោះ ហើយតតិយជនក៏អាចយកអចលនវត្ថុនោះទៅធ្វើការចុះបញ្ជីបាន។ ប៉ុន្តែគួរឱ្យបញ្ជាក់ថា ទោះបីជាបុគ្គលទទួលបានសិទ្ធិលើអចលនវត្ថុនោះ ដោយការចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ

---

[៦៥] កម្មវិធីប្រសិទ្ធិភាពនៃការបណ្ដុះបណ្ដាល ផ្នែករដ្ឋប្បវេណីនៅ នៅសាលាភូមិន្ទចៅក្រម. «សំនួរដែលត្រូវបានគេសួរញឹកញាប់ ស្ដីពីការចាត់ចែងរក្សាការពារ» បោះពុម្ពខែឧសភា ឆ្នាំ២០០៩ ទំព័រ ២៣។

[៦៦] ច្បាប់ស្ដីពីការរក្សាការពារផ្នែករដ្ឋប្បវេណី ចុះថ្ងៃ២២ ខែធ្នូ ឆ្នាំ១៩៨៩, មាត្រា៥៨ ។

ហើយអចលនវត្ថុត្រូវបានទទួលស្គាល់ក្នុងការចុះបញ្ជីក្តី ក៏មិនអាចតតាំងនឹងម្ចាស់បំណុលបានដែរ ប្រសិនបើសាលក្រមចុងក្រោយក្នុងករណីម្ចាស់បំណុល ឬ ដើមបណ្តឹងឈ្នះក្តី។[៦៧]

**កថាភាគទី៣៖ ការដាក់ពាក្យសុំអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន**

នីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន គឺត្រូវបែងចែកជាពីរដំណាក់កាលធំៗ គឺនីតិវិធីនៃការសុំដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្ន និងនីតិវិធីនៃការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន។[៦៨]

យោងតាមមាត្រា២ កថាខណ្ឌ២ នៃច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីនៃប្រទេសជប៉ុន បានកំណត់ថា រាល់ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នត្រូវធ្វើឡើងដោយការដាក់ពាក្យស្នើសុំ។ មានន័យថា ទោះបីជាមានដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្នក្តី ក៏ពុំមានការអនុវត្តឡើយ ប្រសិនបើម្ចាស់បំណុលមិនធ្វើការដាក់ពាក្យស្នើសុំធ្វើការអនុវត្តដីកាសម្រេចនោះ។ ហើយច្បាប់ធ្វើការទុករយៈពេល២សប្តាហ៍ ដើម្បីឱ្យម្ចាស់បំណុលធ្វើការដាក់ពាក្យស្នើសុំការអនុវត្តដីកាសម្រេចនេះ ប្រសិនបើហួសអំឡុងពេល២សប្តាហ៍នេះ ម្ចាស់បំណុលមិនធ្វើការដាក់ពាក្យស្នើសុំការអនុវត្តដីកាសម្រេចទេ នោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះនឹងបាត់បង់អានុភាព។[៦៩]

ប៉ុន្តែបន្ថែមពីនេះទៀត នៅក្នុងអនុក្រឹត្យស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីក៏បានបញ្ជាក់ថា ពាក្យស្នើសុំនេះត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ។ ប៉ុន្តែ នៅក្នុងអនុក្រឹត្យនេះផងដែរក៏បានចែងបញ្ជាក់ឱ្យដឹងថា ការដាក់ពាក្យស្នើសុំចាត់ចែងជាបណ្តោះអាសន្ន និងការដាក់ពាក្យស្នើសុំការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននេះ អាចធ្វើឡើងក្នុងពេលតែមួយ។ ដូចនេះ ក្នុងការអនុវត្តជាក់ស្តែងនៃប្រទេសជប៉ុនក៏គេឃើញថា មានករណីជាច្រើនដោយតុលាការដែលធ្វើការដាក់នូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ក៏ជាស្ថាប័នអនុវត្តដីកាសម្រេចនោះដោយសារតែម្ចាស់បំណុលបានធ្វើការដាក់ពាក្យស្នើសុំការចាត់ចែងជាបណ្តោះអាសន្ន និងការស្នើសុំការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននោះ។ ហេតុនេះ ទើបក្នុងការអនុវត្ត គេមិនចាំបាច់ពាក្យស្នើសុំការអនុវត្តការ

---

[៦៧] Narahara law office「民事保全手続き」(«នីតិវិធីស្តីពីការចាត់ចែងរក្សាការពារ»)
http://abe-narahara.com/service/komonkeiyaku/credit/536/ (បានចូលមើលចុងក្រោយ ៨ កក្កដា ២០២១)។

[៦៨] Narahara law office「民事保全執行の手続き」«នីតិវិធីនៃការអនុវត្តការចាត់ចែងរក្សាការពារ»
http://abe-narahara.com/service/komonkeiyaku/credit/537/ (បានចូលមើលចុងក្រោយ ១២ កក្កដា ២០២១)។

[៦៩] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា៤៣ កថាខណ្ឌ២។

ចាត់ចែងជាបណ្តោះអាសន្ននោះសារជាថ្មីឡើយ។[៧០] ការធ្វើបែបនេះ អាចឱ្យម្ចាស់បំណុលចំណេញទាំងថវិកា និងពេលវេលា ហើយការអនុវត្តដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្ននោះក៏បានលឿន ដោយស្របតាមសារតៈនៃការចាត់ចែងជាបណ្តោះអាសន្ន។

## ផ្នែកទី២៖ ការប្រើប្រាស់ច្បាប់ក្នុងប្រទេសកម្ពុជា

### កថាភាគទី១៖ ការដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នក្នុងប្រទេសកម្ពុជា

ដូចដែលបានរៀបរាប់ ទោះបីករណីដែលបង្ហាញពីមូលហេតុមិនចាំបាច់ដាក់ប្រាតិភោគតាមដីកាសម្រេចក្តី ប៉ុន្តែ ស្ទើរគ្រប់ករណីទាំងអស់ តុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយបង្គាប់ឱ្យមានការ ដាក់ប្រាតិភោគ។ ផ្ទុយពីការអនុវត្តក្នុងប្រទេសជប៉ុន យោងតាមការសង្កេតរបស់អ្នកជំនាញនៃប្រទេសជប៉ុនដែលជំនួយដល់ប្រទេសកម្ពុជាបានបង្ហាញឱ្យឃើញថា ការអនុវត្តជាក់ស្តែងក្នុងការដាក់ ឬ មិនដាក់ប្រាតិភោគតាមដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន គឺស្ទើរគ្រប់ករណីទាំងអស់ តុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយមិនបានបង្គាប់ឱ្យដាក់ប្រាតិភោគឡើយ។

មូលហេតុចម្បងនោះគឺ នីតិវិធីទាក់ទងនឹងការទទួលប្រាតិភោគ ឬការទទួលបន្ទុកកិច្ចការផ្ញើប្រាក់នៅក្នុងតុលាការមិនទាន់បានរៀបចំពេញលេញ។ ពីព្រោះថា បទបញ្ញត្តិទាក់ទងនឹងនីតិវិធីនៃការផ្ញើនៅតុលាការនេះមានត្រឹមតែប្រកាសប៉ុណ្ណោះ ហើយក្នុងប្រកាសនេះដែរ គឺមិនបានកំណត់ពីការគ្រប់គ្រង និងទុកដាក់ការផ្ញើរប្រាក់តុលាការឱ្យបានលម្អិតឡើយ។[៧១] មូលហេតុដទៃទៀត អាចដោយសារតុលាការយល់ថាការខូចខាតដែលបង្កដល់កូនបំណុលមិនមានលក្ខណៈធ្ងន់ធ្ងរ ហើយប្រសិនបើដីកាសម្រេចចាត់ចែងរក្សាការពារនោះបង្គាប់ឱ្យម្ចាស់បំណុលធ្វើប្រាតិភោគ វានាំឱ្យប្រជាជនយល់ថា តុលាការធ្វើការទាមទារប្រាក់ពីប្រជាជន ដែលនាំឱ្យមានមានរូបភាពអាក្រក់ដល់តុលាការ។

---

[៧០] Sedonoriaki និងអ្នកនិពន្ធដទៃទៀត, *「民事保全」(«ការរក្សាការពារផ្នែករដ្ឋប្បវេណី»)* បោះពុម្ពដោយ៖ SEIRIN SYOINលើកទី ៣ ២៦ មេសា ឆ្នាំ២០១៣។

[៧១] Maeda Yota, 「カンボジアにおける民事保全の現状」(«ស្ថានភាពជាក់ស្តែងនៃការចាត់ចែងរក្សាការពារក្នុងប្រទេសកម្ពុជា»）ICD NEWS ទំព័រ១៨។

### កថាភាគទី២៖ អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុក្នុងករណីប្រទេសកម្ពុជា

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ពីសិទ្ធិដែលនឹងបន្តអត្ថិភាព និងសិទ្ធិដែលត្រូវរំលត់ក្រោយការលក់នៃអចលនវត្ថុដោយមានកំណត់ក្នុងមាត្រា៤៣១។ នៅក្នុងមាត្រានេះ កថាខណ្ឌ៣ បានបញ្ជាក់ថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នដែលពុំអាចតតាំងនឹងម្ចាស់បំណុលដែលបានសុំធ្វើការអនុវត្តការចាត់ចែងនោះទេ។ ប៉ុន្តែ បើនិយាយអំពីអានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺពុំមានចែងបញ្ជាក់ច្បាស់ក្នុងច្បាប់ប្រទេសកម្ពុជាឡើយ។ ដូចនេះ អ្នកជំនាញប្រទេសជប៉ុនបានពិនិត្យឃើញបញ្ហាថា ដោយសារច្បាប់មិនបានចែងកំណត់ច្បាស់លាស់ពីអានុភាពនៃអចលនវត្ថុដែលត្រូវបានចាត់ចែងជាបណ្ដោះអាសន្ន នោះនាំឱ្យមានភាពលំបាកថា តើអចលនវត្ថុដែលកំពុងស្ថិតក្នុងការចាត់ចែងជាបណ្ដោះអាសន្ននេះត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីតាមរយៈការផ្ទេរសិទ្ធិដែរ ឬទេ។ ពីព្រោះ យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង អាចមានអានុភាពបាន លុះត្រាតែមានការចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ស្ដីពីការចុះបញ្ជី។[៧២]

ហើយមូលហេតុដែលក្រមនីតិវិធីរដ្ឋប្បវេណី មិនបានកំណត់បញ្ជាក់ឱ្យបានច្បាស់ពីអានុភាពនៃអចលនវត្ថុដែលត្រូវបានអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននេះ ដោយសារក្នុងដំណាក់កាលព្រាងច្បាប់ទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី ប្រព័ន្ធចុះបញ្ជីដីមិនទាន់ត្រូវបានរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ជាហេតុនាំឱ្យពេលអ្នកជំនាញប្រទេសជប៉ុនដែលធ្វើការជំនួយក្នុងការតាក់តែងក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចកំណត់ច្បាស់លាស់ពីអានុភាពនោះបានឡើយ។[៧៣] ដូចនេះ ក្នុងក្រមនីតិវិធីយើងក៏មិនមានចែងច្បាស់លាស់អំពីការអនុញ្ញាតឱ្យចុះបញ្ជីអចលនវត្ថុដែលកំពុងស្ថិតក្រោយការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នបានដោយការព្រមព្រៀងគ្នាតាមរយៈកិច្ចសន្យាទិញលក់ ឬ ផ្ទេរកម្មសិទ្ធិដទៃទៀត។

### កថាភាគទី៣៖ ការដាក់ពាក្យសុំអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន

ការដាក់ពាក្យស្នើសុំការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននេះ វាជាដំណាក់កាលនីតិវិធីមួយដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាផងដែរ។ ដូចនេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានបញ្ជាក់

[៧២] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា១៣៥។

[៧៣] Maeda Yota, 「カンボジアにおける民事保全の現状」(«ស្ថានភាពជាក់ស្ដែងនៃការចាតចែងរក្សាការពារក្នុងប្រទេសកម្ពុជា»）ICD NEWS, ទំព័រ១៩ ។

ឱ្យដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នត្រូវធ្វើឡើងតាមរយៈពាក្យសុំ ដែលពាក្យសុំត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ។[៣៤] ប៉ុន្តែអ្វីដែលខុសប្លែកពីច្បាប់ប្រទេសជប៉ុននោះគឺ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មិនមានមាត្រាណាចែងច្បាស់លាស់ថា ការដាក់ពាក្យស្នើសុំការចាត់ចែងជាបណ្ដោះអាសន្ន និងការដាក់ពាក្យស្នើសុំការអនុវត្តនោះអាចធ្វើឡើងក្នុងពេលតែមួយឡើយ។ ហេតុនេះហើយ ទាក់ទងនឹងការដាក់ពាក្យស្នើសុំការចាត់ចែងជាបណ្ដោះអាសន្ន និងពាក្យស្នើសុំការអនុវត្តនេះអាចធ្វើឡើងក្នុងពេលតែមួយឬទេ ដែលនាំឱ្យមានមតិពីរលើកឡើង។

មតិទីមួយ គឺ ទាក់ទងនឹងទ្រឹស្ដីអវិជ្ជមានៈ ដែលពាក្យសុំឱ្យអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន គួរតែត្រូវបានដាក់ដាច់ដោយ ឡែកពី "ពាក្យសុំដីកាសម្រេច ចាត់ចែងជាបណ្ដោះអាសន្ន"។

យោងតាមទ្រឹស្ដីនេះ គេត្រូវអនុវត្តនូវនីតិវិធីដ៏វែងខាងក្រោម ដែលវាផ្ទុយនឹងភាពចាំបាច់នៃនីតិវិធីចាត់ចែងរក្សាការពារ ដែលត្រូវធ្វើអោយបានលឿន។

"ការបញ្ជូនដីកាសម្រេច" ➡ "ពាក្យសុំឱ្យអនុវត្ត" ➡ "ការរៀបចំចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្ន" ➡ "ការចុះបញ្ជីការរឹបអូសជាបណ្ដោះអាសន្ន"។

ករណីដីកាសម្រេចអំពីការចាត់ចែងជាបណ្ដោះអាសន្ន បានបញ្ជូនទៅឱ្យម្ចាស់បំណុល និង កូនបំណុលក្នុងពេលប្រហាក់ប្រហែលគ្នា គេខ្លាចថាកូនបំណុលធ្វើការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ មុនពេលនីតិវិធីចប់សព្វគ្រប់ដែលនាំឱ្យមានការប៉ះពាល់ដល់ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន។ ដូចនេះ ដើម្បីកុំឱ្យមានស្ថានភាពនេះកើតឡើង គេអាចបញ្ជូនដីកាទៅម្ចាស់បំណុលមុនគេ ហើយពន្យារពេលការបញ្ជូនទៅកូនបំណុលជាបណ្ដោះអាសន្នរហូតដល់ពេលការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្នបានធ្វើរួចរាល់ហើយ។

ចំពោះមួយទៀតគឺ ទ្រឹស្ដីវិជ្ជមានៈ ដោយតាមរយៈ "ពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ" គេក៏អាចដាក់ ពាក្យសុំឱ្យអនុវត្តដីកាសម្រេចនេះផងដែរ ដើម្បីត្រៀមលក្ខណៈចំពោះករណីពាក្យសុំមុនត្រូវគេផ្ដល់ ការយល់ព្រមនៅពេលអនាគត។

ប៉ុន្តែ ទ្រឹស្ដីនេះប្រឆាំងនឹងបញ្ញត្តិនៃមាត្រា ៥៦៤ និង មាត្រា ៣៤៩ ដែលចែងថាពាក្យសុំឱ្យអនុវត្តត្រូវភ្ជាប់ជាមួយនឹង លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។ ករណីគេអាចបំពេញនូវ

[៣៤] ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ០៦ កក្កដា ២០០៦,មាត្រា៥៣២ កថាខណ្ឌ២ និងមាត្រា៥។

លក្ខខណ្ឌទាំងអស់នេះ គេអាចបកស្រាយថា តាមការពិចារណាភាពចាំបាច់ក្នុងការអនុវត្តនីតិវិធី ពាក្យសុំឱ្យអនុវត្តអាចធ្វើតាមរយៈពាក្យសុំដីកាសម្រេចការចាត់ចែងបណ្តោះអាសន្ន។ ភាពចាំបាច់នោះមានដូចជា៖

- មានតម្រូវការខ្ពស់ជាពិសេសការអនុវត្តឱ្យបានលឿន និង ការអនុវត្តដោយសម្ងាត់
- ស្ថាប័នទទួលបន្ទុកចេញដីកាសម្រេចចាត់ចែងរក្សាការពារ ក៏ជាស្ថាប័នទទួលបន្ទុកអនុវត្តដីកានោះផងដែរ
- ខ្លឹមសារនៃការអនុវត្តការចាត់ចែងរក្សាការពារ គឺត្រូវច្បាស់លាស់។ [៧៥]

ដូចនេះ នៅពេលចាប់ផ្តើមជាការប្រសើរត្រូវជ្រើសរើសទ្រឹស្តីទីមួយខាងលើដែលស្របតាមបញ្ញត្តិច្បាប់។ ទោះបីជា យ៉ាងណាក៏ដោយ បើពិចារណាអំពីភាពចាំបាច់ជាក់ស្តែង ការបកស្រាយ និង ទ្រឹស្តីទីពីរខាងលើ អាចមានលទ្ធភាពច្រើន។ ពីព្រោះ ការអនុវត្តនៅប្រទេសជប៉ុន មានបញ្ញត្តិច្បាប់ ដែលបកស្រាយដូចទ្រឹស្តីទីពីរ ខាងលើ។ ក្នុងករណីច្បាប់មិនបានបញ្ញត្តិច្បាស់លាស់ គេត្រូវចាប់អារម្មណ៍ចំពោះសេចក្តីណែនាំនៅពេលទទួលពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ។ មានន័យថា ក្នុងករណីមានពាក្យសុំដែលបំពេញតាមលក្ខខណ្ឌនៃភាពចាំបាច់ជាក់ស្តែងដែលកំណត់ខាងលើ គេគួរណែនាំឱ្យដាក់ពាក្យសុំអនុវត្តដីកាសម្រេចនោះផងដែរ ហើយវាមានប្រយោជន៍ក្នុងការរៀបចំគម្រូពាក្យសុំជាមុនសំរាប់អ្នកដាក់ពាក្យសុំ។

[៧៥] កម្មវិធីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាល ផ្នែករដ្ឋប្បវេណីនៅ នៅសាលាភូមិន្ទចៅក្រម. «សំនួរដែលត្រូវបានគេសួរញឹកញាប់ ស្តីពីការចាត់ចែងរក្សាការពារ» បោះពុម្ពខែឧសភា ឆ្នាំ២០០៩, ទំព័រ ៣៥។

# សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវអំពី «ការចាត់ចែងជាបណ្តោះអាសន្ន» នេះមក យើងអាចសង្កេតឃើញថា របបទាក់ទងនឹងការចាត់ចែងជាបណ្តោះអាសន្នត្រូវបានកើតមានឡើង និងអនុវត្តតាំងពីយូរណាស់មក ហើយនៅក្នុងប្រទេសនានារួមទាំងប្រទេសជប៉ុនដែលមានស្តែងឡើងក្នុងច្បាប់ស្តីពី ការរក្សាការពារផ្នែករដ្ឋប្បវេណី។ ហើយប្រព័ន្ធនេះក៏ត្រូវបាននាំចូលប្រទេសកម្ពុជា ដែលមានចែងបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ របបនេះត្រូវបានប្រើប្រាស់ដោយសារ ការចាត់ចែងជាបណ្តោះអាសន្ននេះ មានគោលបំណងការពារ និងថែរក្សាស្ថានភាពដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារបុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ តាមរយៈការទាមទាររបស់បុគ្គលនោះ។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ការចាត់ចែងជាបណ្តោះអាសន្ននេះមានពីរប្រភេទទៀត គឺការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ដែលនីតិវិធីរបស់ការចាត់ចែងជាបណ្តោះអាសន្នទាំងពីរនេះមិនមានលក្ខណៈខុសប្លែកគ្នាប៉ុន្មានទេ។ អ្វីដែលពិសេសនោះគឺ យើងឃើញថាក្នុងច្បាប់ប្រទេសជប៉ុនធ្វើការបែងចែកការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទជាពីរប្រភេទទៀតគឺ «ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការចាត់ចែង» និង «ការចាត់ចែងជាបណ្តោះអាសន្នហាមឃាត់ការផ្ទេរការកាន់កាប់»។ រីឯការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ទោះបីមិនមានចែងច្បាស់ក្នុងច្បាប់នៃប្រទេសជប៉ុនក្តីក៏គេអាចឃើញមានការអនុវត្តមួយចំនួនដែលមានកំណត់ទាក់ទងនឹងប្រភេទនេះ។ ចំពោះលំហូរនៃនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្ននេះ ដូចបានរៀបរាប់ខាងដើម គឺវាចំណុចដូចគ្នា ដែលមានលក្ខណៈដូចទៅនឹងនីតិវិធីនៃច្បាប់ប្រទេសជប៉ុន។ នៅពេលម្ចាស់បំណុលចង់ការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន នោះម្ចាស់បំណុលត្រូវដាក់ពាក្យសុំ ដើម្បីឱ្យតុលាការពិនិត្យពីសិទ្ធិដែលត្រូវរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ រួចទើបធ្វើការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។ ជាការពិតណាស់ កូនបំណុលក៏អាចធ្វើការការពារសិទ្ធិរបស់ខ្លួន ដោយធ្វើការតវ៉ាចំពោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះបាន ដោយស្របតាមនីតិវិធីដែលបានពន្យល់ខាងដើម។ ជាបន្ទាប់ ទើបតុលាការ ធ្វើការវិនិច្ឆ័យ និងសម្រេចថាដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះមានភាពត្រឹមត្រូវ ឬទេ។

គួរឱ្យបញ្ជាក់ថា ក្រោយពីបានសិក្សាប្រៀបធៀបការចាត់ចែងជាបណ្ដោះអាសន្ន យើងក៏អាចមើលឃើញពីចំណុចខ្លាំង និងចំណុចខ្សោយនៃការចាត់ចែងជាបណ្ដោះអាសន្នរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុន។ នៅប្រទេសកម្ពុជា ដោយហេតុថា បញ្ញត្តិពាក់ព័ន្ធនឹងការចាត់ចែងជាបណ្ដោះអាសន្ននៅមិនទាន់មានលក្ខណៈសម្បូរបែបនៅឡើយ។ ហេតុនេះហើយ យើងអាចសង្កេតឃើញថា មានចម្ងល់មួយចំនួយដែលគេបានលើកឡើងដូចជា នៅពេលការអនុវត្តជាក់ស្ដែងក្នុងការដាក់ ឬ មិនដាក់ប្រាតិភោគតាម ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន គឺស្ទើរគ្រប់ករណីទាំងអស់ តុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយមិនបានបង្គាប់ឱ្យដាក់ប្រាតិភោគឡើយ។ ប៉ុន្តែ ការដាក់ប្រាតិភោគនេះមានសារៈសំខាន់ ដោយសារការដាក់ប្រាតិភោគតាមដីកាសម្រេចនេះ គឺដើម្បីធានាដល់សំណងខូចខាតទៅលើកូនបំណុល។ សំណងខូចខាតនេះ អាចកើតមានឡើងដោយសារការស្នើសុំ ឬការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននេះមានទម្រង់ខុសច្បាប់ រួមទាំងដើម្បីទប់ស្កាត់លើការរំលោភលើសិទ្ធិស្នើសុំចាត់ចែងជាបណ្ដោះអាសន្ន។ ដូចនេះ ទើបការអនុវត្តជាក់ស្ដែងក្នុងប្រទេសជប៉ុន ភាគច្រើនឱ្យតែមានការដាក់ចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ជាគោលការណ៍គឺមានការដាក់ប្រាតិភោគ។ បន្ថែមពីនេះទៀត ទាក់ទងអំពីអានុភាពនៃការចាតចែងជាបណ្ដោះអាសន្នលើអចលនវត្ថុ ដោយនៅក្នុងច្បាប់ស្ដីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីនៃប្រទេសជប៉ុនបានបញ្ជាក់ពី អានុភាពមិនផ្ដាច់មុខនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នលើការហាមឃាត់ការចាត់ចែង។ ផ្ទុយមកវិញ ចំពោះអានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺពុំមានចែងបញ្ជាក់ច្បាស់ក្នុងច្បាប់ប្រទេសកម្ពុជាឡើយ។ ដូចនេះ អ្នកជំនាញប្រទេសជប៉ុនបានពិនិត្យឃើញបញ្ហាថា ដោយសារច្បាប់មិនបានចែងកំណត់ច្បាស់លាស់ពីអានុភាពនៃអចលនវត្ថុដែលត្រូវបានចាត់ចែងជាបណ្ដោះអាសន្ន នោះនាំឱ្យមានភាពលំបាកថាតើអចលនវត្ថុដែលកំពុងស្ថិតក្នុងការចាត់ចែងជាបណ្ដោះអាសន្ននេះត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីតាមរយៈការផ្ទេរសិទ្ធិដែរ ឬទេ។ ជាចុងក្រោយ គឺទាក់ទងអំពីការដាក់ពាក្យសុំការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន។ ដោយសារតែ នៅក្នុងអនុក្រឹត្យស្ដីពី ការរក្សាការពារផ្នែករដ្ឋប្បវេណីបញ្ជាក់ឱ្យដឹងថា ការដាក់ពាក្យស្នើសុំចាត់ចែងជាបណ្ដោះអាសន្ន និងការដាក់ពាក្យស្នើសុំការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននេះ អាចធ្វើឡើងក្នុងពេលតែមួយហេតុនេះ ក្នុងការអនុវត្តជាក់ស្ដែងនៃប្រទេសជប៉ុនក៏គេឃើញថា មានករណីជាច្រើនដោយ ម្ចាស់បំណុលអាចធ្វើការដាក់ពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន និងពាក្យសុំការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននោះក្នុងពេលតែមួយបាន ។ ប៉ុន្តែ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មិនមានមាត្រាណា

ចែងច្បាស់លាស់ថា ការដាក់ពាក្យស្នើសុំការចាត់ចែងជាបណ្តោះអាសន្ន និងការដាក់ពាក្យស្នើសុំការអនុវត្តនោះ អាចធ្វើឡើងក្នុងពេលតែមួយឡើយ។

# អនុសាសន៍

ដោយហេតុថានៅតែមានចំណុចខ្វះចន្លោះនៅឡើយ ទាក់ទងនឹង នីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្ន ដែលនាំឱ្យមានលើកឡើងនូវ ចម្ងល់មួយចំនួនពីអ្នកជំនាញប្រទេសជប៉ុន។ ម្យ៉ាងវិញទៀត ដោយសារប្រទេសកម្ពុជា ជាប្រទេសដែលទទួលយកជំនួយខាងផ្នែកក្រមនីតិវិធីរដ្ឋប្បវេណីក្តី ក៏ក្រមនេះនៅតែមានចំណុចខ្វះចន្លោះមួយចំនួន ដែលទាមទារឱ្យប្រទេសកម្ពុជាធ្វើការដកស្រង់យកចំណុចល្អៗពី ច្បាប់បរទេសយកមកពិចារណាឱ្យត្រូវសមនឹង ស្ថានការណ៍ កាលៈទេសៈនៃប្រទេសយើង ដើម្បីបញ្ចៀសបញ្ហា កុំឱ្យកើតមានឡើងទាំងក្នុងពេលបច្ចុប្បន្នទាំងនៅពេលអនាគត។ ហេតុដូចច្នេះ យើងខ្ញុំ សូមអនុញ្ញាតផ្តល់ជូនជា អនុសាសន៍ដូចខាងក្រោម ៖

- ការរៀបចំកែតម្រូវក្រមនីតិវិធីកម្ពុជាទាក់ទងនឹង ការចាត់ចែងជាបណ្តោះអាសន្ន ដោយធ្វើការកំណត់ច្បាស់លាស់ពី លក្ខខណ្ឌនៃការមិនដាក់ប្រាតិភោគតាមសេចក្តីសម្រេច អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និង រយៈពេលនៃការដាក់ពាក្យសុំការអនុវត្តដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។
- ត្រូវបង្កើត និងពង្រឹងការផ្សព្វផ្សាយអំពីនីតិវិធីនៃការរក្សាការពារឱ្យបានច្រើន តាមរយៈសិក្ខាសាលា ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិចនានា។
- អ្នកច្បាប់គ្រប់មជ្ឈដ្ឋាន គួរតែស្វែងយល់ឱ្យបានស៊ីជម្រៅ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីលើកស្ទួយវិស័យយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ចៅក្រមដែលជាអ្នកសម្រេចសេចក្តី ត្រូវតែធ្វើការសម្រេចសេចក្តីដោយត្រូវពិនិត្យមើលលក្ខខណ្ឌចាំបាច់នានា ដើម្បីសម្រាប់ការចេញដីកាសម្រេចនឹងពិចារណា មុនធ្វើការសម្រេចសេចក្តី។

# ឯកសារយោង

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ**

– ក្រមនីតិរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

– ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

– ច្បាប់ស្តីពីការរក្សាការពារផ្នែករដ្ឋប្បវេណី ចុះថ្ងៃ២២ ខែធ្នូ ឆ្នាំ១៩៨៩។

- **សៀវភៅ**


– ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី(ភាគ២)*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ឆ្នាំ២០០៨។

– ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗឆ្នាំ*. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧។

– Sedonoriaki និងអ្នកនិពន្ធដទៃទៀត, *「民事保全」( «ការរក្សាការពារផ្នែករដ្ឋប្បវេណី»)*, បោះពុម្ពដោយ ៖ SEIRIN SYOINលើកទី៣ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣។

– Engelmann. លោក ណាកាធោ តេអ៊ីឈិធោ, ប្រែសម្រួល «ប្រវត្តិសង្ខេបនៃក្រមនីតិវិធីរដ្ឋប្បវេណី». បោះពុម្ពឆ្នាំ ២០០៧។

– Yukawa Ryo «ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន» ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

– Yamamoto Kazuhiko, *「民事保全」(«ការចាត់ចែងរក្សាការពារ» )* បោះពុម្ពដោយ Nipon Hyoron sha co,Ltd,ឆ្នាំ២០១៤។


- **អត្ថបទបោះពុម្ពផ្សាយផ្សេងទៀត**


_ កម្មវិធីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាល ផ្នែករដ្ឋប្បវេណីនៅ នៅសាលាភូមិន្ទចៅក្រម. «សំនួរដែលត្រូវបានគេសួរញឹកញាប់ ស្តីពីការចាត់ចែងរក្សាការពារ»» បោះពុម្ពខែឧសភា ឆ្នាំ២០០៩។

_ សួង សុភា, ចៅប៊ុនហួន. «នីតិវិធីនៃការចាត់ចែងរក្សាការពារ»ឆ្នាំ២០១៧ ។

_ Matsuo 「カンボジア司法アクセス」(« ប្រព័ន្ធយុត្តាធិកានៅប្រទេសកម្ពុជា»)，ផ្នែកស្រាវជ្រាវនីតិសាស្ត្រនៃសកលវិទ្យាល័យខេអុនៃប្រទេសជប៉ុន ថ្ងៃទី៨ ខែមិនា ឆ្នាំ២០១៣។

_ Maeda Yota, 「カンボジアにおける民事保全の現状」(«ស្ថានភាពជាក់ស្តែងនៃការចាតចែងរក្សាការពារក្នុងប្រទេសកម្ពុជា»）ICD NEWS ទំព័រ១៨។

– Nakayama,「カンボジアの司法 ～始審裁判所～」″ប្រព័ន្ធតុលាការកម្ពុជា សាលាដំបូង′, ICD NEW, ខែធ្នូ ឆ្នាំ ២០១៧។

_ Yokomichi Shunnichi ,«ការសិក្សាទៅលើមាត្រា២៣វគ្គខណ្ឌ៤នៃច្បាប់ស្ដីពីការចាត់ចែងរក្សាការពារ». Keio law Journal 28(ខែកុម្ភៈ ឆ្នាំ ២០១៤)។

- **គេហទំព័រ**

_ Yogohama law office,「仮の地位を定める仮処分について」（«ការចាត់ចែងជាបណ្ដោះអាសន្ន»）http://www.breeze.gr.jp/field/saikenkaisyu/minjihozen_syobun.html (បានចូលមើលចុងក្រោយ៖ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១)។

_ តុលាការរដ្ឋប្បវេណីនៃតំបន់Hiroshima«លិខិតណែនាំទាក់ទងនឹងការដាក់បណ្ដឹងចំពោះការចាត់ចែងរក្សាការ» ទំព័រ១០ https://www.courts.go.jp/hiroshima/vc-files/hiroshima/file/hozen08.pdf (បានចូលមើលចុងក្រោយ៖ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១)។

_ Mikura Hideo「仮処分命令による登記」（«ការចុះបញ្ជីចំពោះការចាត់ចែងជាបណ្ដោះអាសន្ន»）ឆ្នាំ២០១៩ ទំព័រ១៤https://www.tatsumi.co.jp/stream/documents/asakura_19012001_3.pdf (បានចូលមើលចុងក្រោយ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១)។

_ Mitsuho law office「民事保全における担保の基礎について」(«មូលដ្ឋាននៃការដាក់ប្រាតិភោគក្នុងករណីការចាត់ចែងរក្សាការពារ» https://www.mclaw.jp/kigyohomu/26681/?fbclid=IwAR0awbzcb316p7uRbiSpp1uPHuIlL7p412X9TMdALQfKWRzWYX_Qa7kV9vE (បានចូលមើលចុងក្រោយ៖ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១)។

_ Narahara law office「民事保全の手続き」（«នីតិវិធីស្ដីពីការចាត់ចែងរក្សាការពារ» ) http://abe-narahara.com/service/komonkeiyaku/credit/536/ (បានចូលមើលចុងក្រោយថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១)។

_ Narahara law office「民事保全執行の手続き」«នីតិវិធីនៃការអនុវត្តការចាត់ចែងរក្សាការពារ» http://abe-narahara.com/service/komonkeiyaku/credit/537/ (បានចូលមើលចុងក្រោយថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១។

- http://www.kuma-office.jp/article/13515438.html?fbclid=IwAR1c-ghitCxmZxrdCmZimexApDmLTkn540IXAPM4uzB98cRl-IZ4gdwcZ0w (បានចូលមើលចុងក្រោយថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១)។
- Mizuho law office, 「違法な保全の申立や執行による損害賠償責任の基本」（ «សំណងខូចខាតដោយសារការស្នើសុំ ឬការអនុវត្តការចាត់ចែងរក្សាការពារដែលមានទម្រង់ខុសច្បាប់» ）ចុះផ្សាយ ១៧ មិថុនា ២០១៥https://www.mc-law.jp/kigyohomu/19391/ (បានចូលមើលចុងក្រោយ៖ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១)។

# ឧបសម្ព័ន្ធ

# ក្រម

# នីតិវិធីរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# គន្ថីទី ៧
# ការចាត់ចែងរក្សាការពារ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៣០.–** គោលគំនិត

ប្រសិនបើមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬ ប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

**មាត្រា ៥៣១.–** ប្រភេទនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារសំដៅទៅលើការចាត់ចែងនីមួយៗ ដែលមានខ្លឹមសារដូចកំណត់នៅក្នុងចំណុចនីមួយៗ ខាងក្រោមនេះ :

ក-ការរឹបអូសជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ។

ខ-ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ : ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

គ-ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន : ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកាចូល

ជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

**មាត្រា ៥៣២.-** ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន

១-ដីកាសម្រេចក្នុងការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការតាមពាក្យសុំ ។

២-ការអនុវត្តការចាត់ចែងរក្សាការពារ ត្រូវធ្វើឡើងដោយតុលាការ ឬ អាជ្ញាសាលាតាមពាក្យសុំ ។

៣-តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារ តាមបញ្ញត្តិនៃគន្ថីនេះ ត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រា ៣៣៦ (ស្ថាប័នអនុវត្ត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តការចាត់ចែងរក្សាការពារ ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៣.-** សមត្ថកិច្ចផ្ដាច់មុខ

សមត្ថកិច្ចរបស់តុលាការដែលបានកំណត់នៅក្នុងគន្ថីនេះ គឺជាសមត្ថកិច្ចផ្ដាច់មុខ ។

**មាត្រា ៥៣៤.-** របៀបដាក់ពាក្យសុំ

ពាក្យសុំដែលបានកំណត់ខាងក្រោមនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ៈ

ក-ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

ខ-ពាក្យបណ្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ។

គ-ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ។

ឃ-ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ង-ពាក្យបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៥៦១ (បណ្ដឹងជំទាស់) នៃក្រមនេះ ។

ច-ពាក្យសុំឱ្យអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៥.–** ការសម្រេចសេចក្ដីចំពោះនីតិវិធីនៃការរក្សាការពារ ជាអាទិ៍

១-ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ និង នីតិ-វិធីដែលតុលាការធ្វើចំពោះការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តការរក្សាការពារ អាចសួរជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬ ជនដែលពាក់ព័ន្ធផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសាលាដំបូងត្រូវសម្រេចសេចក្ដីអំពីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្ត ដែលធ្វើឡើងដោយអាជ្ញាសាលា ។

**មាត្រា ៥៣៦.–** ការផ្ដល់នូវប្រាតិភោគ

ដើម្បីដាក់ប្រាតិភោគតាមបញ្ញត្តិនៃគន្ថីនេះ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ឬ តុលាការអនុវត្តការរក្សាការពារ ។

**មាត្រា ៥៣៧.–** សោហ៊ុយនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន៥.០០០ (ប្រាំពាន់) រៀល ទៅតុលាការ ។

២-ពេលដាក់ពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារទៅតុលាការអនុវត្តការរក្សាការពារ អ្នកដែលដាក់ពាក្យសុំ ត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការអនុវត្តការរក្សាការពារ ដែលជាសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្តការរក្សាការពារ ។

៣-ប្រសិនបើអ្នកដែលដាក់ពាក្យសុំមិនបានបង់សោហ៊ុយនោះទុកជាមុនទេ តុលា-ការអនុវត្តការរក្សាការពារ អាចលើកចោលពាក្យសុំឱ្យធ្វើការអនុវត្តការរក្សាការពារ ឬ អាចលុបចោលនូវនីតិវិធីអនុវត្តការរក្សាការពារបាន ។

៤-ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំ តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ អាចប្ដឹងជំទាស់បាន ។

៥-ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តការរក្សាការពារចំពោះអាជ្ញាសាលា អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធ តាមបញ្ញត្តិដែលបានកំណត់ផ្សេង ។

**មាត្រា ៥៣៨.-** ការមើលសំណុំរឿងនៃការចាត់ចែងរក្សាការពារ ជាអាទិ៍

១-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ឬ នីតិវិធីដែលតុលាការធ្វើឡើងចំពោះការអនុវត្តរក្សាការពារ អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីតុលាការបាន ដោយបង់ពន្ធ ។

២-ជនដែលបានធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ ចំពោះការអនុវត្តរក្សាការពារដែលធ្វើឡើងដោយអាជ្ញាសាលា អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ពីអាជ្ញាសាលាបាន ដោយបង់ពន្ធ ។

**មាត្រា ៥៣៩.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤

បញ្ញត្តិពីគន្ថីទី ២ ដល់គន្ថីទី ៤ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការចាត់ចែងរក្សាការពារ លើកលែងតែមានបញ្ញត្តិពិសេស ។

## ជំពូកទី ២

## ដីកាសម្រេចរក្សាការពារ

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៤០.-** តុលាការដែលមានសមត្ថកិច្ច

១-រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ ។

២-តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះលើក ទី ១ ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការ ក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែល មានសមត្ថកិច្ចលើអង្គសេចក្តី គឺជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

៣-បើកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃវិវាទ ជាសិទ្ធិ លើបំណុល ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ ស្ថិតនៅកន្លែងរបស់កូនបំណុលទី ៣ ដែល បានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងប្រគល់នាវា ឬ ចលនវត្ថុ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះស្ថិតនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ ។

៤-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នា ផងដែរ ចំពោះករណីដែលកម្មវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ កម្មវត្ថុនៃ វិវាទ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ហើយមានកូនបំណុលទី ៣ ឬ បុគ្គល ដែលមានលក្ខណៈដូចជាកូនបំណុលទី ៣ ។

**មាត្រា ៥៤១.-** ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង សេចក្តីបញ្ជាក់ដំបូង

១-ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរបញ្ជាក់នូវចំណុចដូច បានកំណត់ខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ។

គ-សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ។

ឃ-ភាពចាំបាច់នៃការរក្សាការពារ ។

២-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ គប្បី សរសេរឱ្យ បានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗដែលត្រូវបញ្ជាក់ ។

៣-ចំពោះចំណុច គ និង ឃ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលដាក់ពាក្យសុំ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

**មាត្រា ៥៤២.–** ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ។

**មាត្រា ៥៤៣.–** ការបញ្ជូន

តុលាការត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅភាគី ។

**មាត្រា ៥៤៤.–** បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល

១-ចំពោះសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

## ផ្នែកទី ២
## ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

**មាត្រា ៥៤៥.–** ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

១-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ។

២-ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបាន ទោះបីជាសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ។

**មាត្រា ៥៤៦.–** កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ ។ ប៉ុន្តែ ចំពោះដីកាសម្រេចរឹបអូសចលនវត្ថុជាបណ្តោះអាសន្ន អាចចេញបាន

ដោយមិនចាំបាច់កំណត់កម្មវត្ថុ ។

**មាត្រា ៥៤៧.–** ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន

១-ក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ដែលកូនបំណុលត្រូវផ្ញើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះ-អាសន្ន ។

២-ការផ្ញើប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្ញើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ។

## ផ្នែកទី ៣
## ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

**មាត្រា ៥៤៨.–** ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នជាអាទិ៍

១-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ ។

២-តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

៤-តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការ

ទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានស្ថានភាពពិសេស ដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ ។

**មាត្រា ៥៤៩.–** វិធីចាត់ចែងជាបណ្ដោះអាសន្ន

តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬ មិនធ្វើអំពើណាមួយជាកំណត់ ឬ ឱ្យកូនបំណុលផ្ដល់តាវកាលិក ឬ ឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ។

## ផ្នែកទី ៤
## ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥០.–** ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទៅតុលាការដែលបានចេញដីកាសម្រេចនោះ ។

**មាត្រា ៥៥១.–** ការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍

១-ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្ត តាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្ដី តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងក្រោមនេះ ក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ លុះត្រាតែមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ និង អំពីការដែលមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារការអនុវត្តរក្សាការពារ ។

២-ក្នុងករណីដែលតុលាការនៃបណ្ដឹងជំទាស់បានចេញដីកាសម្រេចរក្សាការពារ បើមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្ដី តាម

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បានដែរ ។

៣-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវលុបចោល ផ្លាស់ប្ដូរ ឬ ទទួលស្គាល់នូវសេចក្ដីសម្រេចដែលបានធ្វើរួចហើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥២.–** ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ។

**មាត្រា ៥៥៣.–** ការបញ្ចប់ការវិនិច្ឆ័យ

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ។ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថា បញ្ចប់ការវិនិច្ឆ័យ ។

**មាត្រា ៥៥៤.–** ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

១-នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្ដូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ ។

២-ចំពោះដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

**មាត្រា ៥៥៥.–** ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន

បើម្ចាស់បំណុលបានទទួលការប្រគល់វត្ថុ ឬ ការបង់ប្រាក់ ឬ ប្រើប្រាស់ឬថែរក្សាគ្រប់គ្រងវត្ថុ ដោយផ្អែកលើដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តុលាការអាចបង្គាប់

ឱ្យម្ចាស់បំណុលបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬ សងប្រាក់ដែលកូនបំណុលបានបង់ ឬ បង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ឬថែរក្សាគ្រប់គ្រងបាន តាមពាក្យសុំរបស់កូនបំណុល នៅក្នុងដីកាសម្រេចដែលលុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ។

**មាត្រា ៥៥៦.-** អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ

ដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ពុំមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ ។ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ ។

## ផ្នែកទី ៥

## ការលុបចោលដីកាសម្រេចរក្សាការពារ

**មាត្រា ៥៥៧.-** ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ជាអាទិ៍

១-តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល ។

២-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានរយៈពេលមិនតិចជាង ២ (ពីរ) សប្ដាហ៍ ។

៣-បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ តាមបញ្ញត្តិនៃកថាខណ្ឌដដែលនោះ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែល

បានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនោះ ត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះ មិនបានដាក់ឡើយ ។

៥-ចំពោះការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៣ ខាងលើនេះ បើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ត្រូវចាត់ទុកជាការដាក់ពាក្យបណ្តឹងអង្គសេចក្តី ។

៦-បើនីតិវិធីមជ្ឈត្តកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ បានចប់មិនមែនដោយសេចក្តីសម្រេចមជ្ឈត្តករ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងអង្គសេចក្តី ក្នុងអំឡុងពេលដូចគ្នានឹងអំឡុងពេលដែលបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ចាប់ពីថ្ងៃដែលនីតិវិធីមជ្ឈត្តកម្មនោះបានចប់ ។

៧-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ ហើយបញ្ញត្តិនៃកថាខណ្ឌទី ៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបណ្តឹងអង្គសេចក្តីត្រូវបានដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ៦ តែក្រោយមកត្រូវបានដកវិញ ឬ ត្រូវបានលើកចោល ។

៨-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចតាមកថាខណ្ឌទី ៣ និង ទី ៧ ។

**មាត្រា ៥៥៨.–** ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព

១-បើមានការរលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សាការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន ។

២-ចំពោះការផ្លាស់ប្តូរស្ថានភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង កថាខណ្ឌទី ២ នៃមាត្រា ៥៥៤ (ដីកា

សម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៥៩.-** ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារស្ថានភាពពិសេស

១-ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះបាន ដោយមានល័ក្ខខ័ណ្ឌតម្រូវឱ្យដាក់ប្រាតិភោគ តាមពាក្យសុំរបស់កូនបំណុល ។

២-ចំពោះស្ថានភាពពិសេសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៥៦០.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍

១-បញ្ញត្តិពីមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) ដល់មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីអំពីការលុបចោលដីកាសម្រេចរក្សាការពារ លើកលែងតែចំពោះការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥៧ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ជាអាទិ៍) ។

២-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្ត

ដូចគ្នា នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការនៃបណ្តឹងអង្គសេចក្តី ផ្សេងពីតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ហើយមានសំណុំរឿងនៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ តុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ ក៏អាចធ្វើការសម្រេចសេចក្តី តាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ផ្នែកទី ៦
## បណ្តឹងជំទាស់

**មាត្រា ៥៦១.-** បណ្តឹងជំទាស់

១-ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ :

ក-ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ ។

ខ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ។

គ-ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៦០ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ជាអាទិ៍) ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់ ។

២-អំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានទេ ។

៣-បញ្ញត្តិនៃមាត្រា ៥៤៣ (ការបញ្ជូន) និង មាត្រា ៥៥៤ (ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) មាត្រា ៥៥២ (ការវិនិច្ឆ័យអំពីការតវ៉ា

ចំពោះដីកាសម្រេចរក្សាការពារ) មាត្រា ៥៥៣ (ការបញ្ចប់ការវិនិច្ឆ័យ) និង មាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ហើយបញ្ញត្តិនៃមាត្រា ៣១៧ (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសេចក្តីសម្រេចដែលអាចប្តឹងជំទាស់បាន បានចូលជាស្ថាពរ ។

៤-ចំពោះការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ (ការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្តរក្សាការពារ ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងករណីដែលមានសំណុំរឿងនៅតុលាការដើម តុលាការដើមនោះក៏អាចធ្វើការសម្រេចសេចក្តីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៥១ នោះបានដែរ ។

## ជំពូកទី ៣

## ការអនុវត្តរក្សាការពារ

**មាត្រា ៥៦២.–** លក្ខខណ្ឌនៃការអនុវត្តរក្សាការពារ

១-ការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត ។

២-ការអនុវត្តរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ (ពីរ) សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល ។

៣-ទោះបីនៅមុនពេលដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ ក៏ការអនុវត្តរក្សាការពារ អាចធ្វើបានដែរ ។

**មាត្រា ៥៦៣.–** ករណីពិសេសនៃតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងតវ៉ារបស់តតិយជន

ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) នៃក្រមនេះក៏ដោយ ក៏បណ្ដឹងតវ៉ារបស់តតិយជន ចំពោះដីកាសម្រេចរក្សាការពារដែលសាលាឧទ្ធរណ៍បានធ្វើ ក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ ។

**មាត្រា ៥៦៤.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងជំពូកនេះ បញ្ញត្តិពីមាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលា ជាអាទិ៍) ដល់មាត្រា ៣៤៥ (បណ្ដឹងជំទាស់ចំពោះដីកាសម្រេចលុបចោល ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៤៨ (អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ) បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៣៤៩ (របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ) កថាខណ្ឌទី ១ នៃមាត្រា ៣៥១ (វិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ) កថាខណ្ឌទី ២ នៃមាត្រា ៣៥៤ (ភាពចាំបាច់នៃរូបមន្តអនុវត្ត និង ស្ថាប័នផ្ដល់រូបមន្តអនុវត្ត) កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ៣៥៥ (ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត) ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ពីមាត្រា ៣៥៧ (ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត) ដល់មាត្រា ៣៥៩ (ការសរសេរចូលទៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត) មាត្រា ៣៦២ (ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ជាអាទិ៍) បញ្ញត្តិនៃមាត្រា ៣៦៤ (បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត) និង មាត្រា ៣៦៥ (បណ្ដឹងតវ៉ារបស់តតិយជន) និង បញ្ញត្តិពីមាត្រា ៣៦៧ (ការសម្រេចសេចក្ដីផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ជាអាទិ៍) ដល់មាត្រា ៣៧០ (ការផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះការអនុវត្តរក្សាការពារ ។

**មាត្រា ៥៦៥.-** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ ។

២-អាជ្ញាសាលាត្រូវធ្វើប្រាក់ដែលបានមកពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន នៅតុលាការដែលខ្លួនស្ថិតនៅ ។

៣-បើមានការបារម្ភថា ចលនវត្ថុដែលការរឹបអូសជាបណ្ដោះអាសន្នត្រូវបានអនុវត្តនឹងចុះតម្លៃយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាត្រូវលក់ចលនវត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុដែលបានកំណត់នៅក្នុងផ្នែកទី ២ ជំពូកទី ២ នៃគន្ថីទី ៦ នៃក្រមនេះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ន ឬ កូនបំណុល ហើយធ្វើប្រាក់ដែលបានមកពីការលក់នោះនៅតុលាការដែលខ្លួនស្ថិតនៅ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ) ពីមាត្រា ៣៨៩ (ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត) ដល់មាត្រា ៣៩២ (ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីដែលប៉ាន់ប្រមាណឃើញថា គ្មានចំនួនសេសសល់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ។

**មាត្រា ៥៦៦.-** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៤០២ (អត្ថន័យនៃការអនុវត្តចំពោះសិទ្ធិលើបំណុល និង តុលាការអនុវត្ត) នៃក្រមនេះ ត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារ ចេញដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលទី ៣ សងទៅកូនបំណុល ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ត្រូវមានសមត្ថ-

កិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្នុងករណីដែលការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ បើកូនបំណុលទី៣បានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលនៅតុលាការ ត្រូវចាត់ទុកថា កូនបំណុលបានផ្ញើប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះភាគដែលលើសពីចំនួនប្រាក់នោះ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ ទី ៣ ទី ៦ ទី៧ ទី ៨ ទី ១០ និង កថាខណ្ឌទី ១១ នៃមាត្រា ៤០៣ (ដីកាសម្រេចរឹបអូស) បញ្ញត្តិពីមាត្រា ៤០៤ (ទំហំនៃការរឹបអូស) ដល់មាត្រា ៤០៨ (ការជូនដំណឹងអំពីការដកពាក្យសុំ ជាអាទិ៍) មាត្រា ៤១១ (ការផ្ញើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១៦ (ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នចំពោះសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ។

**មាត្រា ៥៦៧.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១៧ (កម្មវត្ថុ និង វិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះ ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាកាពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤២០ (ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស

ជាអាទិ៍) វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ នៃមាត្រា ៤២១ (អានុភាពនៃការរឹបអូស) កថាខណ្ឌទី ១ នៃមាត្រា ៤២៤ (ដីកាសម្រេចចាប់ផ្ដើមត្រួតត្រា) មាត្រា ៤២៥ (ដីកាសម្រេចចាប់ផ្ដើមត្រួតត្រា នៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តចំពោះអចលនវត្ថុ) មាត្រា ៤២៧ (ការលុបចោលនីតិវិធីនៃការលក់ដោយបង្ខំដោយសារការបាត់បង់ ជាអាទិ៍ នៃអចលនវត្ថុ) និង មាត្រា ៤២៨ (ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) នៃក្រមនេះ ត្រូវយកមកអនុ-វត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ។

**មាត្រា ៥៦៨.–** ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

១-ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្ដល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ។ របៀបទាំងនេះ អាចអនុវត្តរួមគ្នាបាន ។

២-ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។

៣-ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) មាត្រា ៤៦៥ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយការវិនាសបាត់បង់នាវា ជាអាទិ៍) និង មាត្រា ៤៦៦ (ការផ្ទុកផ្ដាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូស) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះ-អាសន្នតាមរបៀបចុះបញ្ជី ហើយបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៤៥៥ (ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះនាវា និង របៀបអនុវត្ត) កថាខណ្ឌទី ៧ នៃមាត្រា ៤៥៧ (ដីកាសម្រេចចាប់ផ្ដើម ជាអាទិ៍) មាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) និង

មាត្រា ៤៦២ (ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះការអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិត បញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ។

**មាត្រា ៥៦៩.–** ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ដោយធ្វើប្រាក់រំ-ដោះពីការរឹបអូសជាបណ្តោះអាសន្ន

១-បើកូនបំណុលបានផ្ញើប្រាក់ស្មើនឹងចំនួនប្រាក់ដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) នៃក្រមនេះ នៅតុលាការ តុលាការអនុ-វត្តរក្សាការពារ ឬ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ត្រូវលុបចោលនូវការអនុវត្តរឹប អូសជាបណ្តោះអាសន្ន ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៤៥ (បណ្តឹងជំទាស់ចំពោះដីកា សម្រេចលុបចោល ជាអាទិ៍) នៃក្រមនេះ ដែលត្រូវយកអនុវត្តដូចគ្នា នៅក្នុងមាត្រា ៥៦៤ (ការអនុវត្តដូចគ្នា តាមបញ្ញត្តិនៃគន្ថីទី ៦) ក៏ដោយ ក៏ដីកាសម្រេចដែលធ្វើឡើង តាមបញ្ញត្តិ នៃកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមៗដែរ ។

**មាត្រា ៥៧០.–** ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ត្រូវអនុវត្តតាមវិធីដូចគ្នានឹងវិធីអនុវត្តរឹបអូស ជាបណ្តោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំ ។

**មាត្រា ៥៧១.–** អានុភាពនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការ កាន់កាប់

១-បើដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាប់កាប់វត្ថុ និង បង្គាប់ ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យ អាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវ បានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការ ផ្ទេរការកាប់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដោយបិទលិខិតប្រកាស ជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ។

២-បើការចាត់ចែងជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបាន ដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី ។ ប៉ុន្តែ ម្ចាស់បំណុលអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ ។

៣-ជនដែលកាន់កាប់វត្ថុដែលពាក់ព័ន្ធក្រោយពេលការអនុវត្តចាត់ចែងជាបណ្ដោះ-អាសន្ន ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានសន្មតថា កាន់កាប់វត្ថុនោះ ដោយដឹងថា ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះ ត្រូវបានធ្វើហើយ ។